# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ របស់ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូតព្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ខុកញ៉ា ទេពពិទូរ-ក្រសេម.... វណ្ណគតិ រឿងទាយណ៍ ទសាវតារ.... ២២៥

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម .. រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១ រូបឈ្មោះ ហ្វួន-ឆាង (តមក) .......... ២៣៣

" " " ពង្សាវតារប្រទេសចិន (តមក) ...... ២៤៤

ឃុនឧត្តមប្រិជា ចាប-ពិន .. អធិប្បាយសុភាសិត (តមក) .... ២៥២

*ផ្នែកសាសនា*

លោកអាចារ្យ មៀវ-ឆន.... សាសនាវតារ សង្ខេប .......... ២៦៤

ព្រះអាចារ្យ ប៉ាង-ខាត់.... អរិយសច្ចជាពុទ្ធភាសិត (តមក) .... ២៧៥

វណ្ណកតិ

# នារាយណ៍ ទេសាវតារ

## គឺនារាយណ៍ បែងភាគ ដប់គ្រា

ឧកញ៉ា ទេពពិទូ ក្រសេម គន្ថបណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

---

ព្រះជាម្ចាស់ក្នុងលទ្ធិវៃសយ មាន ៣ អង្គ រួមហៅថា ត្រិមិតិ,[១] គឺបានដល់ព្រះព្រហ្មអ្នកសាងលោក ១ ព្រះវិស្ណុ អ្នកថ្នមបរិហារលោក ១ ព្រះសិវៈ អ្នកទំលាយលាងលោក ១ ។ ពាក្យសម្រាប់ពេញព្រះនាមព្រះជាម្ចាស់ទាំង ៣ នេះ គេប្រើត្រឹមមួយម៉ាត់គឺ ឱ ប្រកបដោយអក្សរ ៣ តួ បើនឹងញែកចេញគង់បានជារូបគឺ អ. ឧ. ម. ទាំង ៣ ម៉ាត់នេះ ជាពាក្យជំនួសព្រះនាមនៃព្រះទាំង ៣ អង្គ ឬជាត្រៃសរណគមន៍ក្នុងលទ្ធិវៃសយ ។ លទ្ធិឬសាសនារបស់ព្រះជាម្ចាស់ទាំង ៣ ហៅថា "វៃសយ" ប្រែថា „លទ្ធិដ៏ប្រសើរ" រាប់ថាជាលទ្ធិធំនឹងចាស់ជាងគេនៅក្នុងលោកនេះ ពួកជនជាតិព្រាហ្មណ៍ជាអ្នកទទួលកាន់កាប់លទ្ធិនេះ តាំងអំពីដើមមក ។

---

១ ត្រិមិតិក្នុងលទ្ធិវៃសយមិនមែនមានតែព្រះជាម្ចាស់ប៉ុណ្ណោះ សូម្បីព្រះទេវីក៏មានដែរគឺព្រះសរស្វតី (ព្រះកាយសម្បុរស) ព្រះលក្ស្មី (ព្រះកាយសម្បុរក្រហម) ព្រះភគវតី (ព្រះកាយសម្បុរខ្មៅ) ។ ក្នុងគម្ពីរ វរាហបុរាណៈ ពោលថា ដែលព្រះទេវីមានសម្បុរព្រះកាយ ស ក្រហម-ខ្មៅ ក្តីព្រោះប្រព្រឹត្តទៅតាមត្រៃកាល គឺអតីតកាល បច្ចុប្បន្នកាលនិងអនាគតកាល ។ រឿងត្រិមិតិក្នុងលទ្ធិគ្រិស្តក៏មានដែរ គឺបានដល់ព្រះយេហូវ៉ា ១ ព្រះបិត្ត ១ ព្រះយេស៊ូ ១ ទាំង ៣ នេះរួមជា ១ អង្គជាមួយគ្នា ។

មានសេចក្ដីដំណាលក្នុងខនេះថា វណ្ណៈ ៤ គឺព្រាហ្មណ៍កើតចេញអំពីព្រះឱស្ឋព្រះព្រហ្ម, ព្រះរាជានឹងព្រះរាជវង្សកើតចេញមកអំពីព្រះហស្តស្តាំ-ទ្វេងនៃព្រះព្រហ្ម, វេស្សៈ កើតចេញអំពីព្រះឧរូព្រះព្រហ្ម, សូទ្រៈ កើតចេញអំពីខ្នងព្រះបាទព្រះព្រហ្ម ។ ដោយហេតុពួកព្រាហ្មណ៍កើតអំពីព្រះឱស្ឋដូច្នេះ ព្រះព្រហ្មទើបទ្រង់ព្រះមេត្តាប្រោសឲ្យជាអ្នកទទួលកាន់កាប់លទ្ធិសៃយទាំងមូល, ឯពួកក្សត្រនិង ពួកវេស្សៈ ទោះនឹងរៀនសូត្រគម្ពីរព្រះវេទ ឬចូលកាន់លទ្ធិសៃវបាន វៀរតែពួកសូទ្រៈដែលជាមនុស្សជាន់ទាប នឹងស្ដាប់គម្ពីរព្រះវេទមិនបាន ។

ព្រះជាម្ចាស់ទាំងពីរនេះ ទោះបីជាវិទិយមកប់អានរបស់ពួកជនជាតិហិណ្ឌូទៅ តែចំពោះព្រះព្រហ្មឃើញដូចជាគ្រាន់តែជាអ្នកសាងលោកប៉ុណ្ណោះ មិនបានគិតកំគតការដណ្ដើមអំណាចដូចព្រះពីរអង្គក្រៅនេះ ឯអភិនិហារសេចក្ដីស័ក្តិសិទ្ធិនៃព្រះវិស្ណុ នឹងព្រះសិវៈនោះសោត ឃើញស្រេចហើយតែពួកអ្នកគប់កន គឺបើជាសៃវនិកាយ ក៏គប់គានព្រះសិវថាជាធំជាងគេ បើជាវៃស្ណវនិកាយក៏គប់អានព្រះវិស្ណុថាជាឯកអុកជាងគេ ជូនកាលដល់ទៅមានបង្អាប់គ្នាថា ព្រះឥស្សូរចាញ់ឫទ្ធិព្រះនារាយណ៍ក៏មានដូចយ៉ាងគ្រាមួយនោះ ពួកទេពនិករម៉ែនចុះសម្រុងគ្នាថា ព្រះជាម្ចាស់ទាំងពីរនេះ អង្គណាជាធំជាងអង្គណា? គេទើបអញ្ជើញព្រះទាំងពីរអង្គមកប្រឡងឫទ្ធិគ្នា ព្រះឥស្សូរទ្រង់គេចធនូបីងនឹងបាញ់ព្រះនារាយណ៍ ។

ស្រែកសន្ធាប់តែមួយម៉ាត់ គេនឹងទុកឲ្យក្រកិកក្រកក់ដូចជាក្រមួនត្រូវថ្ងៃ ពួកទេពនិករទើបសម្រេចសន្និដ្ឋានថា ព្រះនារាយណ៍ទន់ឫទ្ធិជាងព្រះឥសូរ ។ រឿងព្រះនារាយណ៍មានឫទ្ធិជាងព្រះឥសូរ គេលើកយ៉ាងឲ្យឃើញមួយទៀត ដូចយ៉ាងគ្រាមួយព្រះឥសូរប្រទានពរឲ្យពួកអសុរមានឫទ្ធិដូចភ្លើង កាលយកដៃទះអ្នកណា ក៏កើតជាភ្លើងឆេះរោលឡើងពួកអសុរចង់លងគ្រមើល លើកដៃឡើងប្រុងនឹងទះព្រះឥសូរ។ ខ្លាចឫទ្ធិដៃភ្លើងក៏ស្ទុះរត់ទៅ; គ្រានោះក្តៅដល់ព្រះនារាយណ៍ ៗ ក៏គោងមកជួយក្រាបពួកអសុរ ។ ដូចការផល់ទៅឲ្យព្រះឥសូរគោរពព្រះនារាយណ៍ក៏មាន ។

មុនដែលនឹងសំដែងរឿងរ៉ាវព្រះនារាយណ៍បែងភាគមកក្រាបសឹកសត្រូវក្នុងយុគនោះៗ សមគួរនឹងចំណែកយុគឲ្យបានយល់ចូលចិត្តជាមុនសិន ។ ការចំណែកយុគនេះ មានរៀងគ្នាជា ២ យ៉ាង គឺចំណែកតាមប្រវត្តិសាស្ត្រ នឹងចំណែកតាមសេចក្តីជឿរប់អានរបស់ព្រាហ្មណ៍ ។

តាមប្រវត្តិសាស្ត្រនោះលោកចំណែកទុកជា ៤ យ៉ាង គឺ:

១– យុគព្រះវេទ ឬត្រៃវេទ មានព្រះគម្ពីរ ៣ ភាគ គឺ:

ក– ឫគវេទ (Rigaveda) ជាគម្ពីរតែងជាលំនាំពាក្យឆន្ទ សម្រាប់ស្មូត្រស្តុតិសរសើរព្រះជាម្ចាស់ ។

ខ– សាមវេទ (Sàmaveda) ជាគម្ពីររៀបរមបទភ្លេងសម្រាប់ស្តុតិទេវតាក្នុងវេលាធ្វើពិធីបូជាយញ្ញ ។

ក- យជុវេទ (Yajurveda) ជាគម្ពីរពណ៌នាសរសើរទេវតាដែលគេប្រមូលឡើងខាងក្រោយ ។

តមកកើតគម្ពីរវេទ ១ ទៀត ហៅថា អថវវេទ (Atharvaveda) ជាគម្ពីរបញ្ចុះពេញដោយគាថាមន្តអាគមស្នេហ៍ សម្រាប់ធ្វើឲ្យមូលមកឬឲ្យប្រាស់ទៅ ។

២- យុគគម្ពីរព្រាហ្មណ៍ ក្នុងយុគនេះសេចក្ដីជឿកាន់យកក្នុងការធ្វើពិធីជារបស់សំខាន់ក្រៃលែង, ពពួកជនទើបនាំគ្នាគប់គាន់ព្រាហ្មណ៍ថាជាអ្នកថ្លៃថ្នូរជាងវណ្ណក្សត្រ ព្រោះព្រាហ្មណ៍ជាម្ចាស់យញ្ញកម្មទាំងពួង, ពួកអរិយកៈបាននាំគ្នាចុះមកនៅក្នុងភូមិភាគប៉ែកខាងត្បូង បានប៉ះនឹងពួកទស្យុ ក៏កើតជាសង្គ្រាមឡើង ឫសីវាល្មិគិបាននិពន្ធមហាកាព្យ គឺរាមាយណៈដ៏ជាដើមរឿងរាមកេរ្តិ៍ ។

៣- យុគឧបនិស័ទៈ ក្នុងយុគនេះ ព្រាហ្មណ៍គេកាន់ថាព្រះព្រហ្មជាព្រះម្ចាស់តែ ១ អង្គ (ប្រហែលទំនងសេចក្ដីគិតឃើញរបស់ពួកឧរុបក្នុងមជ្ឈិមសម័យ ដែលបានទំលាយទេពច្រើនៗចេញ ឲ្យគង់នៅតែរូបព្រះយេស៊ូ ១ ប៉ុណ្ណោះ) ទាំងកាន់ថាជាអាត្មន (atman) របស់លោក ជាអរូបកទេព ទើបបានកើតមានអ្នកទទឹងតស់សាសនាព្រាហ្មណ៍ឡើង ដូចយ៉ាងពួកសំខ្យៈជឿថា មនុស្សកើតមកតោងទទួលទល់ទុក្ខវេទនាគ្មានទីបំផុត

ទើបគិតកែខៃរកផ្លូវឲ្យរួចចាកសង្សារវដ្ត បានតាំងខ្លួនជាសាស្តាប្រដៅលទ្ធិ, ធម៌តាមគាប់ចិត្តខ្លួន ដូចសុប្បិយបរិព្វាជក និងមក្ខលិគោសាលជាដើម ។

៤- យុគពុទ្ធកាល ដ៏ជាផលរបស់ការប្រតិបត្តិលទ្ធិព្រាហ្មណ៍ ។

យុគ ១ យ៉ាងទៀតចែកជា ៤ គឺ

| | | | | | |
|---|---|---|---|---|---|
| ក្ឫតយុគ | = | ៤៨០០ ឆ្នាំសួគ៌ | = | ១,៧២៨,០០០ | ឆ្នាំមនុស្ស |
| ត្រេតាយុគ | = | ៣៦០០ " | = | ១,២៩៦,០០០ | " |
| ទ្វាបរយុគ | = | ២៤០០ " | = | ៨៦៤,០០០ | " |
| កលិយុគ | = | ១២០០ " | = | ៤៣២,០០០ | " ។ |

មួយឆ្នាំមនុស្សស្មើនឹងមួយថ្ងៃសួគ៌ ហើយក្នុង ១ ឆ្នាំមាន ៣៦៥ ថ្ងៃដូចគ្នា ។ ទាំង ៤ យុគនេះរួមជា ១ មហាយុគគឺ ១២,០០០ ឆ្នាំសួគ៌ ឬគិតជា ៤,៣២០,០០០ ឆ្នាំមនុស្ស, មួយពាន់មហាយុគជា ១ ថ្ងៃរបស់ព្រះព្រហ្មសិងហៅថាក័ល្ប[១] យប់នឹងថ្ងៃរបស់ព្រះព្រហ្មវែងស្មើគ្នា ។

ក្នុងយុគទាំង៤ នេះមានហេតុកេតផ្សេងៗគ្នាដូចមានប្រាកដក្នុងគម្ពីរមហាភារតៈ ។

---

១ តាមសេចក្តីជឿរបស់ពួកព្រាហ្មណ៍ថា មានវេលាស្មើនឹង ១២,០០០,០០០ ឆ្នាំសួគ៌ ក័ល្បនេះចែកចេញជា ១.០០០ ភាគ ក្នុង ១ ភាគហៅថា មហាយុគគឺ ១២,០០០ ឆ្នាំសួគ៌ តាមក្នុងត្រៃភូមិកា ត្រង់ដែលនិយាយដោយនរកភូមិ ក្នុងមួយក័ល្បនោះប្រមាណជាមានភ្នំ ១ កំពស់ ១ យោជន៍ទំហំ ៣ យោជន៍ ក្នុងវេលាប្រមាណ ១០០ ឆ្នាំ មានទេវតាយកសំពត់ស៊ំ ទន់មកបោសភ្នំនោះម្តង កាលភ្នំនោះរាបស្មើនឹងផែនដីក៏សំគាល់ថា ១ ក័ល្ប ។

ក្ឫតយុគ ជាយុគដែលមានសត្យធម៌ខ្ពង់ខ្ពស់បំផុត មានព្រះព្រហ្ម ជាទីគោរពបក់ការរបស់នរជនតែ ១ អង្គ, មនុស្សទាំងពួងប្រាសចាក អគតិនូវកិលេសទាំងពួង សុទ្ធតែតាំងនៅក្នុងសត្យធម៌ស្មើគ្នាទាំងអស់ ព្រះព្រហ្មជាទីពឹងនៃយោគីទាំងឡាយ, ព្រះនារាយណ៍ដ៏ជាវិញ្ញាណនៃសត្វទាំងពួង មានព្រះកាយសបរិសុទ្ធ មានព្រះវេទតែត្រឹម ១ គឺឫគវេទ ។

ត្រេតាយុគ សត្យធម៌ថយទៅ ១ ភាគក្នុង ៤ ភាគ ព្រះកាយរបស់ព្រះនារាយណ៍ក្លាយជាសម្បុរក្រហម ពួកមនុស្សនៅគង់នៅក្នុងសេចក្ដីសុចរិត តែកើតចិត្តប៉ុនប៉ងយកផលានិសង្ស នឹងការបំពេញទាន ដើម្បីសុំពរព្រះជាម្ចាស់ ឲ្យខ្លួនបានរបស់វិសេសដែលមិនធ្លាប់មានក្នុងលោក ។

ទ្វាបរយុគ សត្យធម៌ថយទៅពាក់កណ្ដាល ព្រះវរកាយរបស់ព្រះនារាយណ៍ក្លាយជាសម្បុរលឿង ព្រះវេទកើតមានដល់ទៅ ៤ (គឺ ឫគវេទ, សាមវេទ, យជុរវេទ និងអថវ៌វេទ) មនុស្សសិក្សាព្រះវេទក្លាយទៅផ្សេងៗ មិនស្មើគ្នា ពិធីផ្សេងៗក៏មានច្រើនឡើង មនុស្សអ្នកតាំងនៅក្នុងសុចរិតធម៌មានតិច តណ្ហាចូលគ្របសង្កត់ដួងចិត្ត ធ្វើអ្នកប្រព្រឹត្តទៅក្នុងផ្លូវបៀតបៀនគ្នា ។

កលិយុគ សត្យធម៌គង់នៅតែ ១ ភាគ ក្នុង ៤ ភាគ ព្រះកាយរបស់ព្រះនារាយណ៍ក្លាយជាសម្បុរខ្មៅ ៖ ប្រតិបត្តិទាំងពួងក៏មាននៅក្នុងគម្ពីរ

ព្រះវេទថយទៅ  កុសលកម្មនិងបុញ្ញកម្មថយទៅ  ពួកមនុស្សក្រាស់ទៅដោយកិលេស(១) ។

កុងយុគទាំង ៤ នេះ ព្រះវិស្ណុព្រះធំត្រៃបេន  ជាទីគោរពកប់អានរបស់ជនទាំងឡាយ ដែលដូច្នេះ ព្រោះពួកវៃស្ណវៈ (គឺពួកអ្នកកប់អានព្រះវិស្ណុ អ្នកតែងគម្ពីរនេះ) ប្រដៅថា ដើមឡើយមានព្រះជាម្ចាស់តែ ១ ព្រះអង្គ គឺព្រះបរព្រហ្ម, តែគម្ពីរវិកហាបុកណៈថា ព្រះនាកយណ៍គឺព្រះបរព្រហ្មជាអរូបកទេព  ទ្រង់រំពឹងដល់កាលដែលសាងលោកហើយក៏ត្រូវតែទំនុកបម្រុងរក្សាតទៅ  ទើបបែងភាគជារូបកទេព  ជាទេវកដដែលមានកំណើតមិនដូចទេវតានិងមនុស្សទាំងឡាយ  ហើយប្រទានពរដល់ព្រះនាកយណ៍អង្គនេះ ឲ្យជាអ្នកសាងសព្វគ្រប់ទាំងពួង នឹងជាអ្នកបរិហារត្រៃលោកឲ្យមានអំណាចជាធំលើសលែងអ្នកទាំងពួង ។

គមគកងបទបុកណៈពោលថា  កាលសាងសកលលោក ព្រះវិស្ណុបំណាងនឹងសាងសរពើគ្រប់ទាំងពួង  ទើបបែងភាគជា ៣ គឺព្រះអ្នកសាង (ព្រហ្ម), ព្រះអ្នកបរិហារ (វិស្ណុ) នឹងព្រះអ្នកទំលាយ (សិវៈ) ហេតុនោះព្រះទាំង ៣ នេះទើបមិនផ្សេងគ្នា (ដូចគ្នានឹងត្រីទិតរបស់ពួក

១ វេលានេះនៅក្នុងកលិយុគ  អ្នកកាន់សៃវបេសស្ត្រៈផ្ដើមរាប់អានកលិយុគ  តាំងពី ១៨ កុម្ភាព័ន្ធ មុនពុទ្ធសករាជ ២៥៩៩ ឆ្នាំ ព. ស. ២៦៨៥ នៅតែសល់ទៀត ៤២៦, ៩៥៦ ឆ្នាំ  ក៏នឹងផុតកលិយុគ  លោកថានឹងកើតមហាភ័យដល់លោកធាតុ  គឺនឹងមានភ្លើងប្រល័យកល្បឆេះលោកអស់ម្ដង ។

ទ្រុបដូចពោលហើយ ) គឺក្នុងការនេះព្រះអគ្គបានសាងព្រះព្រហ្មអំពីឆ្អឹងជំនីរខាងស្តាំ ព្រះវិស្ណុអំពីឆ្អឹងជំនីរខាងឆ្វេង នឹងព្រះសិវមហាកាលអំពីព្រះឧរ, ប្រហែលជាដោយហេតុនេះ ព្រាហ្មណ៍ខាងវៃស្ណវៈទើបអាងគម្ពីរបុរាណៈថា ព្រះអគ្គីគឺត្រីមូរតិ ដូចពោលហើយ ។

ក្នុងគម្ពីរវិស្ណុបុរាណៈថា ព្រះវិស្ណុជាអ្នកឲ្យកំណើតលោកព្រះអគ្គជាហេតុនៃសេចក្តីកើត នឹងសេចក្តីសាបសូន្យនៃលោក ហេតុនោះព្រះអគ្គីគឺលោក ។

— ក្នុងសម័យព្រះវេទនោះ ព្រះឥន្ទ្រជាព្រះរាជានៃព្រះជាម្ចាស់ទាំងពួង តមកក្នុងយុគគម្ពីរព្រាហ្មណៈ មានព្រះជាម្ចាស់ដែលមានអំណាចខ្ពស់ជាងព្រះឥន្ទ្រ ក៏គឺព្រះអវតារនៃបឋមហេតុ (អនន្ត), ជនជាតិហិណ្ឌូប្រមាណ ១ ភាគ បែរមកកប់អានព្រះវិស្ណុ ដូចអវតារចុះចាកសួគ៌មកជាវិញ្ញាណនៃភូមិកត តែក៏គង់នៅមានពួកខ្លះកប់អានព្រះសិវៈតមករហូតដល់សម័យពុទ្ធកាល ក៏នៅកប់អានព្រះជាម្ចាស់ទាំង ២ នេះ ក្នុងទស្សនាវដ្តីវិទ្យាចារ្យថៃថា ពួកក្រិកនៅក្នុងឥណ្ឌា ប្រមាណក្នុង ព. ស. ២៣១-២៤០ ។

(មានត)

# រឿងរ៉ាវរបស់លោកឧត្តមជាតិចិន ១រូប

## ឈ្មោះហួន-ឆាង

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

[ស្រង់និងប្រែចេញអំពីសៀវភៅ Religieux et Pélerins en terre d'Asie

របស់លោក Goloubew សមាជិក សាលាបារាំងសែសចុងបូព៌ាប្រទេស

(តមក)

ទីក្រុងបាមយ៉ាននោះ ឥឡូវនេះជារបស់អាហ្វខាន នៅលើផ្លូវធំដែលភ្ជាប់ស្រុកប៉័កទ្រីយ៉ាននៅប្រទេសឥណ្ឌា ។ លោកអ្នកដំណើរដ៏មានសទ្ធាជ្រះថ្លា ក៏ធ្វើដំណើរទៅតាមផ្លូវនោះ លុះដល់ទៅស្រុកកបិឝៈ (Kapiça) លោកហួន-ឆាង ក៏បានឈប់សំចតជាវេលាយូរ ។ ទីក្រុងនោះមិនមានអ្វីសេសសល់ដល់មកឥឡូវនេះទេ រៀវលែងតែគ្រាប់បែកកំទេចកំទីប៉ុណ្ណោះ ។ ប៉ុន្តែខាងដើមសម័យកណ្តាល មុនពួកមោហាម៉ែតចូលលុកលុយយកស្រុកនោះបាន ទីក្រុងនោះជាទីប្រជុំខាងសាសនាយ៉ាងសំខាន់ មានកេរ្តិ៍ដំណែលពុទ្ធសាសនាគុះករជាច្រើន ។ នៅទីនោះលោកហួន-ឆាង បានឃើញបានមើលរបស់ (វត្ថុកា) ជាច្រើន បានសាកសួរមនុស្សទាំងឡាយជាច្រើន ។ ហើយលោកក៏ជឿថាខ្លួនលោកដល់ប្រទេសឥណ្ឌាហើយ ។ លោកបានសម្រេចអំពីបំណងនៃការធ្វើដំណើររបស់លោក ហើយមិនបាច់នឹកស្តាយបន្តិច អំពីការដែលមិនបាន

ជឿស្តាប់បង្គាប់ព្រះរាជបញ្ញត្តិ របស់ព្រះរាជាធិរាជព្រះនាមថៃ-ធុង (ដែលបានហាមឃាត់មិនឲ្យលោកចេញមក) ហើយនឹងការដែលលោកបានចេញពោលស្រុកចិនមក ដោយការធ្វើដំណើរយ៉ាងលំបាកវេទនាជាទីបំផុតនោះផង ។

— ៣ —

មុនចុះទៅតាមច្រកភ្នំខៃបេរ ចូលទៅក្នុងទីទំនាបទន្លេឥណ្ឌុស លោកហួន-ឆាង បានចូលមើលភូមិប្រទេស ៤ ដ៏ល្បីល្បាញ ដែលមានពួកអ្នកពុទ្ធសាសនាតែងចូលមើលរាល់គ្នា ព្រោះនៅទីនោះមានរឿងរ៉ាវជាប់ទាក់ទងនឹងរឿងរ៉ាវ របស់ព្រះមនុស្សពុទ្ធជាន់ក្រោយបំផុត ។ មានរោងភ្នំ ១ ដែលព្រះដ៏មានព្រះភាគស្តេចគង់នៅ ក្រោយដែលបានផ្ចាញ់ស្តេចនាគកំណាចឲ្យចុះចាញ់ព្រះអង្គ ហើយព្រះអង្គទុកព្រះឆាយា (ព្រះស្រមោល) របស់ព្រះអង្គជិតជាប់នៅទីនោះ ។ លោកហួន-ឆាង បានចូលទៅក្នុងទីនោះតែមួយអង្គឯក ក្រោយដែលលោកបានប្រាប់ពួកអ្នកដំណើររួមផ្លូវជាមួយនឹងលោក ឲ្យរង់ចាំលោកនៅខាងក្រៅ ។ ឯខាងក្នុងរោងភ្នំនោះងងឹតឈឹង ហើយមុនដំបូង លោកមើលអ្វីមិនឃើញសោះ ។ លោកមានចិត្តប្រកបដោយសទ្ធាជ្រះថ្លាមុតមាំណាស់ ទើបលោកនមស្ការរាប់រយដង ហើបមុខទៅទិសខាងកើត តាំងស្វាធ្យាយព្រះសូត្រទាំងឡាយ ។ វេលានោះ លោកសង្កេតទៅ

ឃើញនៅទីផ្ទាំងរអាងភ្នំនោះ មានពន្លឺយ៉ាងចំឡែកអស្ចារ្យ ១ ហើយស្រាប់តែរលត់ទៅវិញភ្លាម ។ លោកក៏តាំងក្រាបថ្វាយបង្គំទៀត ហើយពន្លឺក៏តាំងកើតប្រាកដឡើងទៀត ។ កន្លងមួយរំពេចនុះឯង រអាងភ្នំនោះក៏កើតមានពន្លឺរស្មីព្រាលទ្រាលឡើង ហើយព្រះឆាយារបស់ព្រះពុទ្ធសាក្យមុនី ក៏ប្រាកដឡើងនៅចំពោះមុខភិក្ខុដែលកំពុងតែមានបីតិត្រេកអរជាខ្លាំង ៗ បើនឹងនិយាយដោយពិតទៅនោះ មិនមែនជាព្រះឆាយារបស់ព្រះអង្គទេ គឺជាពន្លឺរស្មីអ្វីមួយកើតប្រាកដឡើង... ។ ព្រះកាយរបស់ព្រះដ៏មានព្រះភាគ ទាំងស្បង់ចីពររបស់ព្រះអង្គនោះមានពណ៌ក្រហមទុំ ទ្រង់ទ្រាយព្រះភក្ត្ររបស់ព្រះអង្គ ទ្រង់មានអំណាចហើយទ្រង់ញញឹមផង មើលទៅឃើញជាក់ច្បាស់សព្វគ្រប់ព្រមទាំងព្រះលក្ខណៈដែលមាននៅសព្វព្រះកាយរបស់ព្រះអង្គ មានតែផ្កាឈូក ១ ទេដែលជាបល្ល័ង្កនោះ ហាក់ដូចជាងងឹត ។ លោកហ្វូន-ឆាងក៏ក្រាបថ្វាយបង្គំដោយសេចក្ដីគោរព ហើយសូត្រសរសើរព្រះពុទ្ធគុណព្រមទាំងបាចបូជាផ្កាភ្ញីនិងគ្រឿងក្រអូបទាំងឡាយផង ។ ឯពន្លឺរស្មីដ៏អស្ចារ្យនោះ ក៏រលត់បាត់ទៅវិញបន្តិចម្ដង ៗ ។ ទើបលោកភិក្ខុហ្វូន-ឆាងក្រាបថ្វាយបង្គំលាត្រឡប់ចេញមកវិញ ។ ឯព្រាហ្មណ៍ដែលធ្វើជាមគ្គុទ្ទេសក៍ ហើយដែលរង់ចាំលោកនៅមាត់ទ្វាររអាងភ្នំនោះ ក៏បាននិយាយប្រាប់លោកថា "លោកគ្រូ, ប្រសិនបើលោកគ្មានសទ្ធាសុចរិត

ស្មោះត្រង់ព្រមទាំងពោលពាក្យប៉ួនសួនយ៉ាងខ្លាំងគ្នាទេ មុខជាលោកគ្រូមិនបានឃើញនិមិត្តបំផ្លែកអស្ចារ្យដូច្នេះទេ" ។

— ៨ —

យើងមិនបាច់ពោលពណ៌នា អំពីដំណើរដើរផ្លូវដ៏វែងលន្លង់លន្លោចឆ្លងកាត់ប្រទេសឥណ្ឌា របស់លោកពុទ្ធគ្គហ្វួន-ឆាង ដោយសព្វគ្រប់ទេ ។ អ្នកឯណាមួយដែលមានគំនិតចង់គិតសើរើរឿងនេះឡើង រហូតដល់ទៅសេចក្ដីល្អិតល្អោចបន្តិចបន្តួច អំពីការធ្វើដំណើររបស់អ្នកពុទ្ធគ្គដែលល្បីឈ្មោះនោះ ត្រូវអ្នកនោះមើលរឿងក៏ដែលលោក រ៉ុនេគ្រូសេត្រ៍ ជាអ្នកប្រាជ្ញពង្សាវតារដ៏ល្បីល្បាញ ប៉ែកខាងឥណ្ឌូនិងចុងបូព៌ាប្រទេស បានតែងទុកក្នុងសៀវភៅរបស់លោកហៅថា Sur les traces du Bouddha (អំពីគន្លងដំណើររបស់ព្រះពុទ្ធ) នោះចុះ ។

លោកហ្វួន-ឆាង មិនបានគង់នៅក្នុងប្រទេសឥណ្ឌាតិចជាង ១១ ឆ្នាំឡើយ (៦៣០ — ៦៤១) ។ ក្រោយដែលលោកបានសំចតនៅជិតពីរឆ្នាំក្នុងប្រទេសកស្មីរ និងប្រទេសសិន្ធុនោះហើយ លោកក៏ធ្វើដំណើរចូលទៅប្រទេសឥណ្ឌាខាងជើងនោះពីមួយទៅមួយ គ្មានភ្លេចគ្មានខ្វះចន្លោះកន្លែងណាមួយឡើយ គឺគ្រប់ៗតំបន់ដែលព្រះពុទ្ធសាក្យមុនីទ្រង់ធ្លាប់គង់នៅ និងធ្លាប់ទ្រង់សំដែងព្រះធម៌ទេសនា ។ លោកបានកត់ត្រាទុកដោយសព្វគ្រប់ អស់ទាំងទំនៀមទម្លាប់និងរឿងព្រេង ដែល

មានដំណាលទៅគ្រប់ស្រុក ។ ពួកអ្នកស្រុកដែលលោកបានសាកសួរ ក៏នាំគ្នានាំលោកទៅរកមើលវិហារទាំងឡាយ ដែលគេបោះបង់ចោលមកជាច្រើនសតវត្សរ៍ ហើយគេបង្ហាញប្រាប់ព្រះស្តូបដែលចាស់ត្រាំត្រាខ្ទូចខាតអស់ទៅដល់ពាក់កណ្តាលហើយ ហើយលោកក៏ធ្វើប្រទក្សិណព្រះស្តូបនោះដោយស្ងប់ស្ងាត់ ។ ចួនកាលលោកទៅគង់នៅមាត់ឆ្នេរស្រះស្រង់ ដែលមានទឹកនឹងថ្កល់ឥតកម្រើក សឹងមានផ្កាឧប្បលច្រើនដេរដាសពាសពេញ នាំឲ្យនឹកដល់ស្តេចនាគរាជខ្វះ ដែលមានសព្វផ្ទះថ្លា (ទីងសាសនា) ។ ទៅសារណាថជិតក្រុងពេនរេស នោះលោកបានឃើញសួនម្រឹគទាយវ័ន ដែលព្រះពុទ្ធជាម្ចាស់បានត្រាស់ព្រះបឋមទេសនា ។ នៅនគរកុសិនារា គេបានចង្អុលបង្ហាញព្រៃរពោះមួយមានម្លប់ត្រជាក់ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ចូលបរិនិព្វាន ហើយនៅជិតទីនោះ គេធ្វើពិធីបូជាព្រះសព ព្រះសរីរកាយរបស់ព្រះអង្គក្នុងមឈូសដែលស្រោចស្រប់ ដោយគ្រឿងក្រអូបនានា ។ ក្នុងទីបំផុតនៅពុទ្ធគយាលោកបានធ្វើសក្ការបូជា ដើមពោធិព្រឹក្សដែលព្រះអង្គបានត្រាស់នោះ ដោយយកម្រងផ្កានិងគ្រឿងក្រអូប ហើយលោកខុនក្រាបថ្វាយបង្គំនៅខាងមុខព្រះរតនបល្ល័ង្ករបស់ព្រះអង្គ ។ លោកមានសេចក្តីរន្ធត់ស្លុតចិត្តជាខ្លាំង ទប់ទឹកភ្នែកមិនឲ្យហូរចេញមកនោះពុំបានឡើយ ។ តាមទំនងនេះ លោកជាភិក្ខុធម្មតាមិនអាចនឹករលឹកឃើញ ដល់ជាតិខ្លួន

ដែលគន្ទង់ទៅហើយនោះបានឡើយ ។ ប៉ុន្តែលោកអាចដឹងតាមទម្ងន់កំហុសនិងអំពើបាបដែលខ្លួនធ្វើហើយក្នុងសង្សារវដ្ដនេះ ចុះលោកបានសម្រេចមគ្គផល ដល់ថ្នាក់ឈានសមាបត្តិណាមួយដែរឬទេ? លោកឥតគិតនឹកនាអំពីសេចក្ដីនឿយហត់សោះឡើយ ទាំងសេចក្ដីលំបាកគោកយ៉ាកនានា ដែលលោកខំអត់ធន់ទ្រាំទ្រមកក្នុងការធ្វើដំណើរយ៉ាងឆ្ងាយបំផុត នោះក៏ឥតមានគ្រោះថ្នាក់អ្វីក្នុងរវាងផ្លូវ តែមានជាច្រើនដង ដែលលោកបានចៀសវាងរួចរួតពីគ្រោះថ្នាក់ទៅ បានដោយមានហេតុដ៏អស្ចារ្យ ។ នៅវេលាដែលលោកកំពុងពិនិត្យពិចារណាមើលដើមព្រះជ្រៃដ៏មានពួរយ៉ាងយ៉ាំមាំនិងទន់ភ្លន់ មានដើមសម្បុរដូចជាទៀន មានសន្លឹកពណ៌បៃតងទន្ទឹងក្ដេកជានិច្ចនោះ លោកត្រឡប់មានគំនិតគិតឃើញហាក់ដូចជាជាក់ស្ដែងណាស់ នៅឱកាសដែលកងទ័ពមារធ្វើអំពើផ្ចាល-ផ្ចាញ់ព្រះពោធិសត្វ នៅវេលាដែលព្រះអង្គតាំងព្រះទ័យស៊ូងស្វាធយ៉ាងវិសេស ហើយទ្រង់បានខំទ្រាំទ្រតទល់នឹងកងទ័ពរបស់មារាធិរាជ... ។ ចូរយើងមើលក្នុងសេចក្ដីពយាការរបស់លោកថាដូច្នេះ កាលនោះ ក្រុងមារាធិរាជបានដំណឹងថា ព្រះពោធិសត្វនឹងបានសម្រេចនូវប្រាជ្ញាញាណដ៏បវរបូណ៌ ក៏ខំរកឧបាយបំផ្លិចបំផ្លាញ ហើយធ្វើឲ្យព្រះទ័យព្រះអង្គរំភើបរញ្ជួយ ។ វេលានោះ មារមានសេចក្ដីសោយសោកខ្លាចក្រែងហើយស្វែងរកឧបាយកលគ្រប់យ៉ាង ទើបក្រុងមារកេណ្ឌពលបិសាចរៀប

បំផាញកងទ័ពមារ កាន់សុទ្ធគ្រឿងអាវុធលើកជាកងទ័ពចេញទៅ ដើម្បីបំភិតបំភ័យព្រះបរមពោធិសត្វ ។ នៅក្នុងវេលាគ្រានោះ មានខ្យល់ព្យុះយ៉ាងខ្លាំងបក់មក ហើយមានភ្លៀងធ្លាក់ចុះមកគគ្រុកគគ្រាក ផ្គរលាន់ ក៏គំរាមជាខ្លាំងលើផ្ទៃអាកាស ទាំងរន្ទះក៏ផ្ដាលប្រេកតទៅសព្វទិសាក្នុងនភាល័យដ៏ងងឹត ។ ខណៈនោះ មានបាញ់ភ្លើងបាញ់ផ្សែង ភ្លៀងខ្សាច់និងគ្រាប់ព្រិលជាដុំថ្ម បាចសាចស្រោចស្រប់ចុះមកជំនួសលំពែងទីងវែល ហើយនិងធ្នូ-សរ-ស្នា ។ ទៅវេលាកំពុងប្រយុទ្ធនោះ ព្រះពោធិសត្វមានព្រះទ័យយ៉ាងចុះស៊ប់ស្ងួនក្នុងព្រះមហាករុណា ។ អស់ទាំងគ្រឿងអាវុធរបស់ពួកខ្មាំងសត្រូវ ក៏ប្រែក្លាយទៅជាផ្កាឈូក ។ កងទ័ពមារក៏មានសេចក្ដីភិតភ័យតក្កមា ហើយនាំគ្នារត់ទៅយ៉ាងប្រញាប់ប្រញាល់ បាត់អស់ទៅក្នុងរំពេចនុ៎ះឯង ។

— ៩ —

លោកហួន-ធាន បានសំណាក់នៅក្នុងតំបន់ពុទ្ធគយា ជាវេលា ១ សប្ដាហ៍ជាងបន្តិច ។ រួចលោកចេញទៅនៅស្រុកនាលន្ទា ដែលជាទីក្រុងសិក្សាយ៉ាងល្បីល្បាញក្នុងដែនបេង្គាល់ នៅទីនោះមានពួកគ្រូវិសេស ៗ បង្ហាត់បង្រៀនលទ្ធិមហាយាន ដែលពួកលោកសង្ឃក្មេងៗ និងពួកឧបាសក-ឧបាសិកា ដែលអាស្រ័យសិក្សារៀនសូត្រនៅទីនោះ មានចំនួនរាប់ទាំងពាន់ៗ រូបរាល់ៗឆ្នាំ ។ នៅវេលាក្រោយភ្លៀងក្នុង

រដូវក្ដៅ ជារដូវរាំងក្រៀងនោះ លោកក៏ឈប់បង្អង់ការសិក្សាជាមួយនឹងពួកភិក្ខុនាលន្ទាទាំងនោះ ដើម្បីចេញដំណើរទៅកាន់ក្រុងរាជគ្រឹះ ដែលជាទីក្រុងចាស់នៃរាជអាណាចក្រមគធៈ ។

នៅពេលដែលលោកទៅដល់នោះ ទីក្រុងនោះក្លាយជាទីក្រុងស្ងាត់ នៅកណ្ដាលព្រៃធំ ជាទីអាស្រ័យនៅនៃសត្វខ្លានឹងដំរីព្រៃទាំងឡាយ ។ លោកហ្វួន ឆាង ក៏ដើរវង់ជុំវិញទីបរិវេណដ៏ធំទូលាយនោះ រូបលោកដើរទៅតាមស្នាមកំពែងដែលបាក់បែកខ្ទេចខ្ទីទាំងនោះ ។ ចំណែកឯទីក្រុងក៏មានទំនងដូចគ្នាដែរ គឺវៀរពេយតូចទៅជាភូមិមួយយ៉ាងតូច នៅកណ្ដាលស្មៅខ្ពស់ៗ មានផ្លូវដើរមួយតូច សម្រាប់ដើរចូលទៅកាន់ទីនោះៗ លោកពុទ្ធជាតិចិនបានពោលបញ្ជាក់ថា "គ្រប់ទិសទាំងអស់នៅទីនោះគេមើលទៅឃើញតែព្រៃឈើកនក: ដែលមានតែផ្ការីកស្គុះស្គាយពាល់ផ្លូវផ្ទាំ ហើយមានស្រទាប់ផ្កាក្រហមព្រាលដូចសម្បុរមាស" ។

នៅក្នុងសម័យដែលក្រុងរាជគ្រឹះ ជាទីប្រជុំក៏រុងរឿងនៃពុទ្ធសាសនិកជនដ៏មានសទ្ធាជ្រះថ្លានៅឡើយនោះ មានរឿងទំនៀមពីបុរាណមួយដំណាលទុកមក ដែលលោកហ្វួន ឆាង បានពោលសរសេរក្នុងសេចក្ដីរាយការរបស់លោកថា: "នៅទិសខាងលិចទីក្រុងមានភ្នំវិបុល ។ តាមរឿងរ៉ាវដែលអ្នកស្រុកដំណាល អំពីរឿងភ្នំនោះដូច្នេះ: នៅទិសខាងជើងប្រែបជើងភ្នំ ត្រង់ទិសនិរតីនៃភ្នំនោះ ពីដើមមកធ្លាប់មានជ្រោះទឹក

ក្តៅចំនួន ៥០០, ដល់មកឥឡូវនេះ នៅសល់តែត្រឹម ៤-១០ ប៉ុណ្ណោះ ប៉ុន្តែជ្រោះខ្លះត្រជាក់អស់ហើយ ជ្រោះខ្លះនៅក្តៅឧណ្ហ ៗ មិនមានជ្រោះណាមួយនៅក្តៅស្ពុះពោះឡើយ ។ ជ្រោះទាំងនោះហូរចេញមកអំពីស្រះអនវតត្ត: នៅខាងជើងមហាបពិតហិមាលយា ហើយហូរកួលទៅតាមក្រោមដីរហូតដល់កន្លែងនេះ ។ ទឹកជ្រោះទាំងនោះថ្លាហើយស្អាត មានរសជាតិដូចទឹកស្រះជាដើមចមទុះឯង ។ ក្នុងខ្សែទឹកនោះដេរដាសដោយតាបនរក មានចំនួន ៥០០ រណ្តៅ ។ អំណាចភ្លើងនៅពីក្រោមដី មានអណ្តាតភ្លើងឆាបឆួលទឹកទាំងនោះឲ្យក្តៅឡើង ។ នៅគ្រប់ៗ រន្ធប្រហោង ដែលមានទឹកជ្រោះហូរចេញមកទាំងប៉ុន្មាននោះ គេបានយកថ្មចំម្ញាក់ដាក់ខ្ទប់មាត់ទឹក ។ ចួនកាលគេធ្វើជារូបក្បាលសិង្ហ ឬក្បាលដំរី ចួនកាលគេយកថ្មមកធ្វើជាខបន្ហូរទឹកសម្រាប់ឲ្យទឹកហូរចេញទៅតាមខ្ទប់នោះក៏មាន ។ នៅពីខាងក្រោមទឹកទាំងនោះ គេបានសាងជាអាងថ្មឡើង ។ មានមនុស្សចេញមកពីគ្រប់ៗ ប្រទេស ដើម្បីទៅចុះងូតទឹកក្នុងអាងថ្មនោះ ។ មានមនុស្សជាចំនួនច្រើនដែលមានជម្ងឺរ៉ា ក្រោយដែលបានងូតទឹកនោះរួចហើយ ត្រឡប់បានសះជាពល់គ្នា” ។

☼

☼ ☼

លោកហ្វូន-ឆាង កាលបានត្រឡប់មកស្រុកនាលន្ទាវិញលោកក៏សំណាក់នៅទីនោះអស់វេលាយូរ ដើម្បីសិក្សារបៀបវេយ្យាករណ៍ និង

របៀបភាសាសំស្រ្កឹត ហើយលោកបានចេះដឹងបរិបូណ៌ ក្នុងក្បួនគម្ពីរដីកាដែលគេបានរៀបរៀងជាភាសានេះ ។ ដោយមានពួកព្រាហ្មណ៍ដែលល្បីឈ្មោះខាងវិទ្យាសាស្រ្ត នឹងមានសំដីថ្វីមាត់ពូកែជាអ្នកបង្ហាត់បង្រៀន ទើបលោកមានចំណេះចេះដឹងស្ទាត់ ក្នុងបរមត្ថវិជ្ជារបស់ឥណ្ឌា ។

កាលលោកពុទ្ធគុត្ត ដើរចេញពីស្រុកនាលន្ទាទៅនោះ លោកបានចូលទៅមើលទីក្រុងនឹងកំពង់មាត់សមុទ្រតាំឡូយ ដែលនៅមាត់ពាមទន្លេគង្គា ។ លោកមានបំណងបង់ចូងទៅកោះសីលង់ ។ ប៉ុន្តែពួកលោកសង្ឃដែលមានសេចក្តីនឿយហត់ ក្នុងការធ្វើដំណើរទៅជាមួយនឹងលោក បាននិយាយពន្យល់លោកឲ្យធ្វើដំណើរដើរទៅតាមផ្លូវផ្សេងវិញ ។ លោកអស់នោះនិយាយនឹងលោកថា "ការធ្វើដំណើរទៅកាន់ប្រទេសនោះ មិនចាំបាច់ធ្វើដំណើរតាមនាវាជាវេលាយូរ នៅវេលាដែលមានខ្យល់បក់ព្រាសមក មានរលកធំៗ ហើយមានពួកបិសាចទុច្ចរិត ចាំធ្វើឲ្យលោកមានអន្តរាយតាំងពាន់យ៉ាងនោះឡើយ ។ គួរតែលោកចេញដើរទៅកាន់ជ្រោយនៅជ្រុងទិសអាគ្នេយ៍ នៃប្រទេសឥណ្ឌាខាងត្បូងវិញ តាមផ្លូវនេះ យើងនឹងអាចទៅដល់កោះសីលង់តាមជើងទឹក ក្នុងរយៈវេលាតែត្រឹម ៣ ថ្ងៃ ។ ទោះបីលោកត្រូវការឡើងទូក ដើរកាត់ច្រោះប្រកក្តុយ៉ាងណាក្តី លោកអាចនឹងធ្វើដំណើរទៅ

បានដោយសុខសប្បាយ ឥតមានអន្តរាយអ្វីឡើយ" ។ លោកហ្ជួន-តាង ក៏ខ្វល់ស្តាប់ពាក្យខ្លួនដ៏សុចរិតនោះ ហើយក៏ចាប់ដើរផ្លូវទៅក្នុងប្រទេសឥណ្ឌាខាងត្បូង ដោយបានដើរកាត់ប្រទេសជាច្រើនដែរនៅជិតមាត់សមុទ្រ ។ ក្នុងវេលានោះ មានកើតចលាចលនៅកោះស៊ីឡង់ ។ ទើបលោកគ្រូហ្ជួន-តាង លះបង់គំនិតដើមគ្រប់ប៉ុណ្ណោះ ហើយលោកត្រឡប់មកតាមផ្លូវដដែលវិញ ។

— ៣០ —

រឿងរ៉ាវដែលលោកហ្ជួន-តាង បានពោលពីការធ្វើដំណើររបស់លោកទុកមកឲ្យយើងនេះ គួរកប់រួមក្នុងពួករឿងបែបច្បាប់សម្រាប់អក្សរ-សាស្ត្រចិនបាន អក្សរសាស្ត្រនេះមានដំឡៃថ្លៃថ្នូរ ព្រមទាំងជាក្បួនខាងភូមិសាស្ត្រសាសនា ហើយជាក្បួនវេនទុក្រមយ៉ាងធំទូលាយបរិបូណ៌ដោយរឿងរ៉ាវគ្រប់មុខ ។ លោកឥតសាវ័ន្ធបានពោលទុកថា: "លោកហ្ជួន - តាង នោះគេអាចហៅថាជាលោកចៅសានត្យាស របស់ឥណ្ឌាក៏បាន; ការពិត លោក (ហ្ជួន-តាង) បានដើរទៅសព្វទិន្ទ គឺពីទិសខាងលិចទៅខាងកើត, ពីខាងជើងរហូតទៅដល់ចុងខាងត្បូង តំបន់ណាដែលលោកមិនបានចូលទៅមើលដោយខ្លួនលោក លោកក៏បានពោលទុកតាមចំនួនដែលមានសាក្សីគួរជឿបាន ដែលលោកបានពិគ្រោះសួរផង, គេទុកលោកជាអ្នកប្រាជ្ញមគ្គុទ្ទេសក៍នៃជនជាតិឥណ្ឌាទាំងពួង

(មានត)

# ពង្សាវតារប្រទេសចិន

(តមក)

ក្នុងកាលតក្កាវៀននេះឯង  មានក្បួនខ្នាតសៀវភៅដែលពោលពីរឿងកំរោងព្រះពុទ្ធសាសនាជាច្រើន  អ្នកប្រាជ្ញប្រវត្តិសាស្ត្រទើបនឹងស្រាវជ្រាវគិតគូរយកចេញ  មើលដឹងសេចក្តីជាក់ច្បាស់ក្នុងកាលឥឡូវនេះឯង  ទើបឃើញមានសេចក្តីនិយាយពីចំណោះ  ក្នុងព្រះពុទ្ធសាសនាជាច្រើន ៗ  ភូមិប្រទេសរបស់តក្កាវៀននេះ  មានអាណាខេត្តពីស្រុកកុលជា  រហូតដល់ស្រុកគួន-ហួង  ទឹងតាំងពីស្រុកកាក់គារ៍ដល់ស្រុកខូ-តាន  តាមតំបន់អស់នេះសឹងជាថាវរេត្ត  ដែលជាសិល្បកម្មរបស់ក្រិកលាយគ្នានឹងបែបរបស់ពុទ្ធសាសនា  របៀបចនារបស់ចិនក្តី  របស់ជប៉ុនក្តី  សឹងនាំយកគំរូបែបផែនពីពួកអស់នេះជាច្រើន  គឺថាពួកតក្កាវៀនក្នុងសម័យនោះ  សឹងមានសេចក្តីចំរើនរុងរឿងប្រហែលៗនឹងចិនដែរ ។

ក្នុងវាង់ព្រះពុទ្ធសករាជ ៤០០ នោះ  អាណាចក្រតក្កាវៀន  ក្នុងទួរគីស្តង់ខាងកើតបានធ្លាក់ទៅជាស្រុកចំណុះរបស់ចិន  ចំពួកដែលចិនហៅថា "ជីមកង់" គឺជាស្រុកចាត់បញ្ជូនគ្រឿងបណ្ណាការថ្វាយក្រុងចិន  តែកាលដែលស្រុកចិនកើតចលាចលវឹកវរឡើងនៅវេលា ១៨ ឆ្នាំនោះ  គឺតាំងពីពុទ្ធសករាជ ៥៥១ ដល់ពុទ្ធសករាជ ៥៦៨ ។ ពួកអស់នេះក៏នាំគ្នាដកខ្លួនចេញពីអំណាចចិនតាំងឥស្សរៈឡើង  កាលដែលព្រះបាទ

ក្វាង-វូទី ទ្រង់បានប្រាបប្រាមតាំងអាណាចក្រចិនជាថ្មីឡើង ហើយក៏មិនបានយកព្រះទ័យទុកដាក់នឹងរួបរួមពួកអស់នោះ ឲ្យមកនៅក្រោមអំណាចដូចកាលពីមុនទៀត ហេតុនេះ ទើបពួកតក្កាវៀនទាំង ២ ស្រុក គឺកុលជាំនឹងខូ-តាន អាស្រ័យកំឡាំងរបស់ពួកហ៊ូន បានដណ្តើមយកខែត្រដៃនក័ប—គាវមកបែងចែកគ្នា ក្នុងសម័យដែលពួកហ៊ូនមានអំណាចមកនៅជាជំនួសពួកចិន ។ ឯពួកហ៊ូននោះមានប្រយោជន៍ដ៏សំខាន់ ក្នុងការដែលខ្លួនផ្សាយអំណាចចេញទៅខាងផ្លូវនេះ ព្រោះវេលានោះពួកហ៊ូនដែលនៅក្នុងអ័ល-តៃ, កិគីសេស៍នឹងគូប៊ី ច្រើនជាទីសមុទ្រខ្សាច់ឬជាទីស្ងួតក្រៀមក្រោះ ។ ចំណែកខាងភូមិប្រទេសនៅតក្កាវៀននេះ ដូចជាតាមឆ្នេរទន្លេតារិម ជាទីមានដីជាតិល្អអាហារត្រីសាច់ក៏មានបរិបូណ៌ ។ មួយវិញទៀត ពួកហ៊ូនត្រូវការឃុំរក្សាផ្លូវថ្នល់មួយហៅថា "ថ្នល់សូត្រ" ដែលជាផ្លូវគមនាគមន៍ សម្រាប់ពួកអ្នកជំនួញនាំជំនួញចេញចូលបាន រវាងបូព៌ាទិសប្រទេស នឹងអណាចក្រប៉ារធ័នឹងមហាណាចក្ររ៉ោម ។

## រឿងមេទ័ព ប៉ុន-ចៅ

មានមេទ័ពចិនម្នាក់ឈ្មោះ ប៉ុន—ចៅ បានពោលតាមយោបល់យល់ឃើញថា ការដែលទួរគីស្ថង់ធ្លាក់ទៅនៅក្នុងកណ្តាប់ដៃពួកហ៊ូននោះ ប្រហែលគ្នានឹងកាត់ដៃចិនម្ខាងដាច់ចេញទៅ ទើបលោកមេទ័ព ប៉ុន-ចៅ

បានទំប្រឹងធ្វើសង្គ្រាមនឹងពួកហួនដល់ ៣០ ឆ្នាំ  ដើម្បីពង្រីកអំណាចចិនឲ្យរីកធំឡើងទៀត  នឹងត្រូវការរួបរួមអាណាចក្រទួរស្គង់មកចូលក្នុងផែនដីរបស់ចិនទាំងអស់ ។

មេទ័ព ប៉ុន-ចៅ កើតក្នុងត្រកូលខ្ពង់ខ្ពស់ ជាអ្នកប្រាជ្ញប្រចាំព្រះអង្គរបស់ព្រះបាទ អ៊ឹង-ទី មានប្អូនស្រីម្នាក់ឈ្មោះ ប៉ុន-ហួយ-ប៉ុន ជាស្ត្រីអ្នកតែងរឿង (កវីនី) ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាដំបូងរបស់បូព៌ាប្រទេស ។ ចំណែកឯមេទ័ព ប៉ុន-ចៅ ចូលចិត្តប្រើដាវច្រើនជាងប្រើពិត (ប៉ាក់កាសរសេរអក្សរចិន) ក្នុងកាលនោះព្រះបាទ ក្វាង-វូទី ទ្រង់ទិវង្គតទៅហើយ តាំងពីពុទ្ធសករាជ ៦០០ ។ ព្រះមហាក្សត្រចិនដែលគ្រងរាជ្យជាដំណតមក ទ្រង់ព្រះនាមព្រះបាទ ម៉ិង-ទី ជាក្សត្រចិនអង្គដំបូង ដែលបានចូលកាន់ព្រះពុទ្ធសាសនា ។ ក្នុងឆ្នាំពុទ្ធសករាជ ៦១៦ មេទ័ព ប៉ុន-ចៅ នឹងមេទ័ពម្នាក់ទៀតឈ្មោះ ទា-គូ បានច្បាំងឈ្នះពួកហួនក្នុងខែត្របារកូល ហើយធ្វើឲ្យចិនមានអំណាចក្នុងខែត្រនេះ រួចលើកហួសចូលទៅក្នុងខែត្រ ក័ច-គារ៍ បង្គាប់បង្ខំឲ្យប្រទេស ខូ-តាន នឹង ក័ច-គារ៍ ព្រមជាចំណុះក្រុងចិន បានសម្រេចក្នុងពុទ្ធសករាជ ៦១៧ ទើបនាំឲ្យស្រុកផ្សេងៗ ក្នុងទួរស្គង់ព្រមចុះចូលឡើងមកក្រុងចិនផង ។ លុះតមកក្នុងពុទ្ធសករាជ ៦១៨ ព្រះបាទ ម៉ិង-ទី ក៏សោយទិវង្គតទៅ កាលដំណឹងនេះបានផ្សាយទៅដល់ប្រទេសទួរស្គង់ៗ ក៏រឹងទទឹងតាំងជា

ក៏ស្រុះទៀត ហើយក្នុងគ្រានេះ ទ័ពស្គន់បានអាស្រ័យកម្លាំងពួកហ្វូន ជួយផង ពួកចិននិងទ័ពស្គន់ក៏តាំងចាប់ច្បាំងគ្នាទៀតយ៉ាងសំបើម ក្នុង វេលានោះមេទ័ពប៊ុន-ចៅ មិនបាននៅក្នុងទីនោះទេ ត្រឡប់ទៅស្រុក ចិនវិញ (ដោយព្រះមហាក្សត្រចិនទ្រង់ត្រាស់ហៅដោយហេតុអ្វីមិនប្រាកដ) ។ ក្នុងគ្រានោះ ពួកទ័ពស្គន់បានប្រទូសរ៉ាយពួកទាហានចិនឲ្យទន់ខ្សោយ ថយកំឡាំងទៅជាច្រើន តែលុះដល់មេទ័ពប៊ុន-ចៅត្រឡប់មកដល់វិញពួក ទាហានចិនក៏មានកំឡាំងខ្លាំងពូកែទៀតវិញ ទើបធ្វើឲ្យប្រទេសទ័ពស្គន់ ភាគខាងកើត ធ្លាក់ទៅនៅក្រោមអំណាចចិនយ៉ាងកប់មួយសាទៀត ។

ជ័យជំនះអស់នេះ ស្រុកចិនបានមកសឹងតែមិនបាច់បង់ខាតអ្វី ឡើយ ។ ពិតមែនតែមេទ័ពប៊ុន-ចៅ បានទទួលទាហានថែមៗមកទៀត ក្នុងមួយគ្រាៗ អំពីទីផ្សេងៗ ក្នុងប្រទេសចិន តែពួកដែលចូលមកធ្វើជា ទាហាននេះ សុទ្ធតែជាពួកអ្នកតស៊ូអន្តរាយ ដែលស្ម័គ្រចិត្តស្វែងរកទ្រព្យ សម្បត្តិអំពីចម្បាំង ។ មួយទៀត មេទ័ព ប៊ុន-ចៅ ចូលចិត្តជួលជនអ្នក ស្រុកអាយមកធ្វើជាទាហាន ដោយមានគំនិតគិតឃើញថា ការប្រើ មនុស្សព្រៃឲ្យច្បាំងតស៊ូនឹងមនុស្សព្រៃ ជាយុទ្ធវិធីល្អបំផុត ។ មួយវិញ ទៀតក្នុងខេត្តយ៉ា-កេនក្ដ ខេត្តក័ច-គាវក្ដ មានភូមិប្រទេសស្រស់បស់ ធំទូលាយ ហើយមានជីជាតិល្អផង ការដែលយកកងទាហានទៅទុកនៅ ទីនោះ ក៏មិនជាការបង់ខាតសោហ៊ុយប្រទេសចិនប៉ុន្មានឡើយ ។ ក្រៅពី

នេះមេទ័ព ប៊ុន-ចៅ បានប្រើវិធី នាំយកពួកទាហានឈ្លបមួយពួក ទៅតស៊ូទឹងពួកឯទៀត ៗ ព្រោះពួកជនអស់នោះមានពួកខ្លះមានការស្អប់ចងអាឃាតគ្នាទៅវិញទៅមក ហើយស្ម័គ្រចិត្តទឹងហែកសាច់គ្នាស៊ីទៅវិញទៅមកផង ៗ វិធីរបស់មេទ័ព ប៊ុន-ចៅនេះ នៅមានប្រទេសធំៗដែលមានស្រុកចំណុះច្រើនៗ និយមយកមកប្រើដល់សម័យសព្វថ្ងៃនេះ ៗ មេទ័ព ប៊ុន-ចៅ បាននាំកំឡាំងទាហាន ខូ-គាន ទៅច្បាំងប្រហារជីវិតក្សត្រគិច-គារ៍ ដែលបានតាំងឥស្សរៈរឹងទទឹងតស៊ូទឹងមេទ័ព ប៊ុន-ចៅ ហើយតមកក្នុងឆ្នាំពុទ្ធសករាជ ៦៣១ មេទ័ព ប៊ុន-ចៅ យកកំឡាំងទាហានគិច-គារ៍ ទៅវាយយកស្រុកយ៉ាំកេន្ទ ៗ ចំណែកឯព្រះចៅផែនដីយូ-អេជីខាងប្រទេសកណ្តាល បានធ្វើស្ពានមេត្រីយ៉ាំងជិតស្និទ្ធនឹងមេទ័ពទួកៃនេះ ៗ ដោយផ្លូវស្ពានមេត្រីយ៉ាំងល្អនេះ ជាហេតុឲ្យព្រះចៅផែនដីយូ-អេជីមួយអង្គ ចាត់រាជទូតទៅសុំក្សត្រីក្រុងចិនក្នុងរាជវង្សហ៊ានយកមកអភិសេក តែពួករាជសំណាក់លោ-យ៉ាំងមិនព្រមឲ្យ ពួកយូ-អេជី ក៏ខឹងនឹងក្រុងចិនជាខ្លាំង ទើបកើតសង្គ្រាមឡើងក្នុងពុទ្ធសករាជ ៦៣១ កងទ័ពយូ-អេជីមានមេទ័ពឈ្មោះ " សា-ហ៊ុ " បានលើកចូលទៅច្បាំងនឹងទ័ពចិន ៗ ចំណែកខាងមេទ័ពប៊ុន-ចៅ បានប្រើឧបាយយុទ្ធវិធីឲ្យខ្មាំងសត្រូវអត់បាយស្លាប់នៅលើភ្នំទួលមួយ ហើយកងទាហាន យូ-អេជី ក៏ដល់នូវសេចក្តីវិនាសខ្ទេចខ្ទីអស់ទៅ ៗ តាំងពីនោះមក ពួកមហាកជានៅ

ប្រទេសឥណ្ឌា) ដែលហ៊ានឃុំឃាំងពួកទូតចិនទៀត ហើយប្រែ ត្រឡប់ជាចងស្ពានមេត្រីនឹងចិន ឲ្យកាន់តែស្និទ្ធស្នាលថែមឡើងទៀត ។ មេទ័ព ប៉ុន-ហៅ តាំងភ្នាក់ហាននៅស្រុកកុលជា ជាអ្នកសម្រេចរាជការ នៅប្រទេសទួគីស្តង់ ហើយបានចាត់ឲ្យនាយទាហានរបស់ខ្លួនម្នាក់ទៅ ត្រួតត្រាប្រចាំស្រុកកាស-គារ៍ ។ គ្រានោះនៅមានក្សត្រអង្គមួយ ក្នុង តំបន់នោះ នៅរឹងទទឹងនឹងអំណាចចិន គឺព្រះចៅផែនដីស្រុកការ៉ាការ លុះ ក្នុងឆ្នាំពុទ្ធសករាជ ៦៣៧ ទើបមេទ័ព ប៉ុន-ហៅ នាំយកទាហានកុលជា ទៅច្បាំងតទល់នឹងក្សត្រអង្គនោះ ដល់ទៅធ្វើគត់ព្រះជន្មក្សត្រនោះបាន ផង ។ មានសេចក្តីដំណាលថា ពួកទាហានរបស់មេទ័ព ប៉ុន-ហៅ បាន សម្លាប់ពួកមនុស្សរបស់ក្សត្រការ៉ាការដល់ចំនួន ៥.០០០ នាក់ ហើយចាប់ យកទៅធ្វើជាឈ្លើយបានដល់ ១.៥០០០ នាក់ ។

នៅគ្រានេះ អាណាចក្រទួគីស្តង់ ត្រូវកងទ័ពចិនប្រាបប្រាមយ៉ាង រាបទាបទៅគ្រប់អន្លើ ហើយនៅតាមដងទន្លេតារីមនឹង យ៉ុល-ឌុល នោះ មិនថាក្សត្រ ចោរ ឬសេដ្ឋីអ្នកមានអ្នកក្រទេ សឹងធ្លាក់ទៅនៅក្នុងអំណាច នៃព្រះចៅក្រុងចិនទាំងអស់ ។ ព្រះចៅអធិរាជក្រុងចិនទ្រង់ព្រះនាម ហូ-ទី គ្រងរាជ្យនៅក្រុង លោ-យ៉ាំង ជាវេលា ១៧ ឆ្នាំ គឺតាំងពី ពុទ្ធសករាជ ៦៣២ ដល់ពុទ្ធសករាជ ៦៤៨ ជាមហាក្សត្រាធិរាជដែល មានបុណ្យអំណាចធំបំផុត មិនធ្លាប់មានក្សត្រចិនអង្គណា មានអំណាចស្មើ

អធិប្បាយសុភាសិត

# ឃុនឧត្តមប្រិជា ជាប-ពិន

រៀបរៀង (តមក)

## ២០- កុំឈ្លោះនឹងស្រី កុំក្ដីនឹងគ្នា(១)

ពាក្យនេះលោកពោលជាពាក្យឃាត់

កុំឲ្យប្រុសៗ ធ្វើក្អាំងក្អាត់ ទាស់មាត់ទាស់កឈ្លោះវិវាទ ។
ដ្បិតលោកចាត់ស្រីទៅជាមេប៉ែក ចំឡែកពីប្រុសដោយធម្មជាតិ
ទាំងចិត្តគំនិតឫកមារយាទ សំនៀងឃ្លាតពីប្រុសមិនដូចគ្នា ។
ធម្មតាស្រីៗ ចិត្តមិនធឹង ច្រើនឆាប់ខឹងតែឆាប់ជា
ប្រុសណាឆាប់ខឹងទទឹងប៉ះពារ ឈ្លោះទាស់ទែងគ្នាជាមិនខាន ។
ទើបលោកថា "កុំឈ្លោះនឹងស្រី" ក៏អាប់សួស្ដីដល់ខ្លួនប្រាណ
មិនបានជាការអ្វីប៉ុន្មាន បានតែរំខានចិត្តអាត្មា ។
មួយទៀតទុកជាប្រុសឬស្រី មិនត្រូវកើតក្ដីអ្វីនឹងគ្នា
ព្រោះក្ដីតែងខូចខាតទ្រព្យា ទាំងអស់ទាំងគ្នាទាំងឈ្នះចាញ់ ។
អ្នកឈ្នះក៏ដាច់ទ្រព្យធនធាន នាំឲ្យរំខានចិត្តខ្វល់ខ្វាញ់
ចំណែកខាងឯអ្នកដែលចាញ់ ខូចទ្រព្យកើតខ្លាញ់យ៉ាងក្រៃលែង ។

---

១ ន័យ១ៈថា "កុំឈ្លោះនឹងស្រី កុំក្ដីនឹងចិន" ។ ពាក្យនេះត្រូវមិនគ្រប់សម័យទេ ។

២១- ក្តិតម៉ងសម នៅប្រមាទជិះឈរនេះគោលៀន

ពាក្យនេះលោកពោលជាពាក្យឡក

ជាពាក្យបន្ទោសប្តូចំអក    ឲ្យស្កកគំនិតអ្នកប្រមាទ ។
គឺមនុស្សអ្នកតូចអ្នកល្ងង់ខ្លៅ    តែខ្លៅគេងកាងគិតរាវអាច
ចង់បានយសសក្តិធំហួសមាឌ    ទំងខាតកម្លាំងនាំរំខាន ។
ហេតុនេះអ្នកប្រាជ្ញចាស់លោកស្តី    ថា "អ្វីហួសមាឌកុំចង់បាន"
តែខំបំពេសហួសប្រមាណ    ទំងខ្ចប់ខ្លួនប្រាណឥតអំពើ ។

២២- ក្តិតតែអង្គុយ កាន្លុយតែចាក់

ពាក្យនេះលោកប្រៀបយ៉ាងចំហុត

តាមភាពនៃមនុស្សមានពុតត្បុត    ដើម្បីស្គាល់ពុតមនុស្សចិត្តវៀច ។
គឺមនុស្សមុយៗបែបម៉ែសៗ    អង្ហុយក្លិនសៗ ទន់ពកៀច
សំដីល្អកល្អិនល្អល្អៀចៗ    តែមានចិត្តគៀចកលឧបាយ ។
មនុស្សបែបយ៉ាងនេះក៏សឹងមាន    យើងបានឃើញហើយកុំមើលងាយ
ត្រូវតែប្រយ័ត្នការសម្លាយ    កុំបីពាយងាយមនុស្សនេះឡើយ ។

២៣- ក្មេងអាងយំ ពាលអាងឫជំ ចាស់អាងស្លាប់[១]

ពាក្យនេះលោកពោលតាមធម្មតា

ដែលយើងធ្លាប់គិតពិចារណា    គឺឃើញថាពិតឥតកុហក ។

---

១ ម្យ៉ាងទៀតថា ពាលអាងកាប់ ចាស់អាងស្លាប់ ក្មេងអាងយំ ។

ចំនៀមក្មេងតូចដែលនៅខ្ចី  បើកើតមួយម៉ៅកករល្អក់
ទឹងរឿងអ្វីមួយតែងខ្ចិចខ្ចក់  ផ្ចិចផ្ចក់កងចិត្តឥតគណនា ។
ច្រើនអាងតែយំដាក់ជាមុខ  រំអុកឲ្យចាស់លោមលួងព៌
រឿងនេះតែងមានជាធម្មតា  កូនក្មេងណា ៗ ក៏មិនខាន ។
ឯពួកមនុស្សពាលមិនអាងយំ  អាងតែប្រដំទាត់ដាក់ប្រាន
ចាក់កាប់សម្លាប់យ៉ាងក្លាហាន  ដោយចិត្តសាមាន្យរបស់វា ។
ឯមនុស្សចាស់ៗចំណាស់ហើយ  មិនដូច្នោះឡើយព្រោះដក
ច្រើនតែប្រជុំនិយាយគ្នា  អាងតែមរណាដាក់ជាមុខ ។

២៤- ក្របីស្នែងកែកា  មនុស្សស្រលៀងក្អែក
កុំឲ្យដើរចូល

ពាក្យនេះបោរាណលោកឧបមា

ជាពាក្យប្រៀបធៀបបែបប្រស្នា  ឲ្យយើងពល់គ្នាចំលះបង់ ។
ពាក្យថា "ក្របីមានស្នែងកែក" គឺមនុស្សចិត្តបែកមិនទៀងត្រង់
មិនកាន់តាមធម៌ព្រះពុទ្ធអង្គ  លោកឲ្យលះបង់កុំចូលជិត ។
ពាក្យថា "មនុស្សកែកក្អែកស្រលៀង" គឺមនុស្សលំអៀងចាកការពិត
ចិត្តកៀចវៀចវេរធ្វើទុច្ចរិត  ហាមកុំដើរជិតកុំដើរចូល ។

២៥- ក្រអីចំណោះ ក្រកៅស្នូផ្ទត់ ធំផងបទីទុយ

ពាក្យនេះជាពាក្យពោលចំអន់

ក្នុងពេលណាមួយដែលបានគ្រាន់ ព្រោះខ្លួនឃើញទាន់ផ្លូវកើតត្រូវ ។
ដែលក្នុងចំណោមគេទាំងឡាយ កំពុងខ្វល់ខ្វាយមិនឃើញផ្លូវ
ហើយខ្លួនតែម្នាក់គិតឃើញត្រូវ ក្នុងផ្លូវការងារឬគម្រោះ ។
អ្នកដែលបានឃើញឬផ្លូវកើត តែងពោលបន្ទុតថាដូច្នេះ
គឺថា "ក្រអីនឹងចំណោះ- ក្រកៅស្នូងតិះនបទំទុយ" ។

២៦- ក្រមុំជណ្ដើរម្ដាយ មេម៉ាយជណ្ដើរចិត្ត

ពាក្យនេះលោកពោលតាមធម្មតា

នៃស្ត្រីដែលនៅជាកញ្ញា គឺថាក្រមុំព្រហ្មចារី ។
អ្នកណាចង់បានជាភរិយា ត្រូវតែនាំគ្នាចូលទៅស្ដី
ដល់ម្ដាយឪពុកទើបគប្បី តាមផ្លូវលោកិយពីព្រេងនាយ ។
ព្រោះស្រីក្រមុំតូចទ្រលុក នៅក្នុងបន្ទុកឪពុកម្ដាយ
មិនអាចសម្រេចលើរូបកាយ ចាត់ចាយខ្លួនឯងពុំទាន់បាន ។
បើដល់ទៅជាស់ជាមេម៉ាយ ទើបអាចចំណាយរៀបខ្លួនប្រាណ
តាមខ្លួនពេញចិត្តល្មមប្រមាណ ព្រោះគេធ្លាប់បានរៀបមុខម្ដង ។
អ្នកដែលជណ្ដើរត្រូវស្រួលចិត្ត បញ្ជាក់ឲ្យពិតតាមទំនង
កុំចរលោកហួសរលង បើគេស្ម័គ្រផងសមយកចុះ ។

## ២៧- ក្រមុំមិនដែលស្លូត ចង្កូតមិនដែលជិត

ពាក្យនេះលោកពោលតាមធម្មតា

ស្ត្រីក្រមុំជាកញ្ញា　　តែងមានចិន្តាបែបខ្ជិបខ្ជក់ ៗ
ឆាប់ខឹងឆាប់ជាមួយរំពេច　　បានស្រួលបន្តិចៈគេចង៉ុចង៉ក់
បើស្តីបន្ទោសតែងតក់ម៉ក់　　ខ្ជិចខ្ជក់ខេវខឹងរតបើគិត ៗ
មិនទាន់មានប្តីត្រៅប្រយ័ត្ន　　ការពារខ្ទឹងម៉ាត់អស់ពីចិត្ត
កុំបីបណ្តោយភ្លោយគំនិត　　ខ្លាចក្រែងប្រព្រឹត្តក្បត់លោកិយ ៗ
ម្តាយទឹងផុតពុកប្តូរមេបា　　គេថ្នមគេក្សាត្រាប្រណី
លំបាកដូចគេថែកូនខ្ចី　　ទម្រាំមានប្តីទើបរបូត ៗ
ហេតុនេះបុរាណទើបពោលថា　　ក្រមុំកញ្ញាមិនដែលស្លូត
លោកប្រៀបគួរនាដូចចង្កូត　　នឹកឆាកធ្វេះៗ មិនដែលស្ងៀម ៗ

## ២៨- ក្អែកាអួយ ជាក្អែកាជប់

នេះជាពាក្យចាស់មិនមែនថ្មី

ដែលប្រាជ្ញបុរាណលោកបានស្តី　　ប្រាប់ជនប្រុសស្រីផងទាំងឡាយ ៗ
គឺជាពាក្យប្រៀបធៀបប្រឌិត　　ពីការប្រព្រឹត្តការបរិយាយ
នៃពាក្យសំដីតែងប្រែក្លាយ　　វេងឆ្ងាយដោយពោលតៗទៅ ៗ
ធម្មតាអ្នកដឹងរឿងអ្វី　　ជារឿងល្អៗ ស្អាតជ្រៅៗ
របែងបាំងបិទពុំជិតនៅ　　ដោយចង់ប្រាប់ទៅអ្នកដទៃ ៗ

បើខប់បិទបាំងរឿងប្លែកៗ ក្នុងទ្រូងស្ទើរបែកសញ្ញែកក្រែ
ខប់ណាស់បានត្រឹមតែបីថ្ងៃ សម័យណាមួយគង់ភ្ញាក់បាន ។
តែពេលចេញហើយមានតែល្អៀង មិនទៀងឃ្លៀងឃ្លាតចាកដើមដាន
ប្លែកៗគិតៗម្តងពុំមាន មិនយូរប៉ុន្មាន ១ ជា ១០ ។
រឿងនេះសឹងមាននិទានពិត សម័យអតីតលោកប្រាព្ធ
អំពីក្អែក ១ ជាក្អែក ១០ ដែលខប់ឲ្យនៅគិតពុំបាន ។
ថាមានបុរសឈ្មោះចៅជា នាងសុខសោភាល្អកល្យាណ
ទើបរៀបការថ្មីដោយក្សេមក្សាន្ត មិនយូរប៉ុន្មានចៅជានោះ ។
ទៅក្នុងព្រៃក្រៅផ្ទះបន្តិច ដោយកិច្ចធុរៈគឺទៅជុះ
បានឃើញការុងប្រាក់នៅនោះ ដែលគេដាក់ចុះលើផែនដី ។
ប្រាក់នោះអាចលទឹងអាខូច ជាមនុស្សកំហូចឥតផ្ទឹមបី
ក៏ទើបបោកគេបានថ្មីៗ មកសូន្យសញ្ញីស្លាប់នៅនោះ ។
ចៅជាបានឃើញការុងប្រាក់ ដែលធ្លាក់នៅដីប្របព្រៃជុះ
ក៏ជីកកប់ទុកក្នុងទីនោះ ហើយដើរបំពោះទៅផ្ទះវិញ ។
ក៏ប្រាប់នាងសុខប្រពន្ធនោះ ថាអញទៅជុះអម្បាញ់មិញ
បានឃើញក្អែក ១ ក៏ហើរចេញ ពីទ្វារជុះមិញចូលក្នុងព្រៃ ។
ប្រពន្ធឮហើយផ្សួលក្នុងចិត្ត តេះបើឲ្យបិទបាំងខ្ទាំងនៃក្រែ
បិទទុកមិនបានប៉ុន្មានថ្ងៃ សម័យខាងក្រោយភ្ញាក់ប្រាប់ក្លាយ ។

ថាក្អែក ២ ចេញពីប្ដូមក ឯក្ដាយក៏យកទៅបរិយាយ
ប្រាប់ឪពុកថា ៣ កាន់តែក្លាយ ដល់គេនាំឲ្យក្លាយជា ១០ ។
ដំណើរនោះប្លែកកើតអស្ចារ្យ ទាល់តែកជការស៊ើបសួរសព្វ
រកចុងរកដើមសាត្រឡប់ មកជួបបញ្ចប់លើចៅជា ។
សួរថាហេតុម្ដេចក៏ដូច្នោះ ឯចៅជានោះឆ្លើយប្រាប់ថា
ខ្ញុំពោលនេះឯងជាប្រស្នា ព្រោះថាខ្ញុំរើសការ៉ុងប្រាក់ ។
នៅក្នុងទីព្រៃមួយកន្ទេង ខ្ញុំក្រែងគេថាឯងលួចលាក់
ទើបខ្ញុំមិនប្រាប់គេថាប្រាក់ ខ្ញុំជីកកប់ដាក់នៅមួយជុំ ។
ហើយខ្ញុំបង្កើតពាក្យឲ្យប្លែក ថាក្អែក ១ ចេញពីខ្លួនខ្ញុំ
ដើម្បីធ្វើរឿងឲ្យសុខុម ត្រាក្រោយទើបខ្ញុំនិយាយដោះ ។
ៗជការបានជាពដូច្នោះឯង ក៏បែងរំលែកចែកប្រាក់នោះ
ឲ្យទៅចៅជាដោយសង្គ្រោះ ពីព្រោះគាត់ប៉ុនរក្សាទ្រព្យ ។
ហេតុនេះទើបប្រាជ្ញបុរាណ ពោលថា "ក្អែក១ ជាក្អែក ១០"
ដោយយករឿងនេះមកប្រាព្ធ ប្រសព្វនឹងពាក្យមនុស្សត្រូវគ្នា ។

២៩ – ខឹងចំអក, ឲ្យតំរែក

សុភាសិតនេះប្រាជ្ញបុរាណ
លោកពោលប្រដៅយើងគ្រប់ប្រាណ ឲ្យមានសន្ដានចិត្តសន្ដោស ។
កាលបើកើតខឹងពីរឿងអ្វី គប្បីប្រយ័ត្នកុំឲ្យថ្កោស

តែខឹងក្តុកក្តាំងហួសកំណាស រមែងកើតទោសទុក្ខពាន់ពាន់ ។
ខឹងខុសខូចខាតប្រមាទខុស វែងធ្វើកហុសជាច្រើនលន់
ហេតុនេះលោកថាត្រូវអត់ធន់ ធ្វើចិត្តឲ្យធ្ងន់ទើបបានសុខ ។
ការខ្សត់ការទាល់ក្រគោកយ៉ាក រមែងពិបាកពុំស្រណុក
ពិបាកស្លៀកពាក់ចាយស៊ីចុក កើតទុក្ខច្រើនយ៉ាងមិនមែនតិច ។
បើខ្លាចក្រខ្សត់ត្រូវលៃលក ប្រឹងរៀនប្រឹងរកធ្វើការកិច្ច
បានទ្រព្យសម្បត្តិទោះច្រើនតិច ត្រូវគិតដូចម្តេចឲ្យបានគង់ ។
កុំចាយផ្តេសផ្តាសឥតបើគិត ត្រូវក្បិតត្រូវក្បៀតប្រៀតការង់
ឲ្យទ្រព្យធនធានបានគង់ទ្រង់ ពេញវង្សតាមវគ្គអ្នកខំរក ។

## ៣០- ខ្លាពឹងព្រៃ, ព្រៃពឹងខ្លា

ពាក្យនេះពោលត្រង់ទីងប្រស្នា

បុរាណប្រៀបធៀបរៀបឧបមា ឲ្យយើងគ្រប់គ្នាដឹងតាមពិត ។
ថាធម្មតាខ្លាតែងប្រស្រ័យ ពួនពឹងទីងព្រៃធំជិតស្និទ្ធ
ជាទីជ្រកខ្លួនពួនចាំងបិទ រកព្រជីវិតជាសត្វ ។
ពួកខ្លាអាស្រ័យនៅព្រៃណា ព្រៃនោះមុខជាជាទីស្ងាត់
ដោយមនុស្សមិនដើរទៅមកកាត់ ព្រោះខ្លាចពួកសត្វសាហាវក្រៃ ។
ព្រៃនោះសុខព្រោះមនុស្សមិនកាប់ ដាព្រៃមានភ័ព្វមិនមានភ័យ
ហេតុនេះបុរាណដ៏ឈ្លាសវៃ ថា "ខ្លាពឹងព្រៃ, ព្រៃពឹងខ្លា" ។

រឿងនេះជារឿងពិតប្រាកដ   ប្រាជ្ញលោកកំណត់តាមធម្មតា
នៃមនុស្សនឹងសត្វគ្រប់ភាសា   គោងពឹងពាក់គ្នាទៅទើបបាន ។
អ្នកតូចគោងពឹងនឹងអ្នកធំ   អ្នកធំពឹងតូចទើបសុខសាន្ត
នឹងនៅម្នាក់ឯងពេលពុំបាន   ពុំសុខសាន្តត្រាណដូចពឹងឡើយ ។

## ៣១- ខ្លាម៉ិនខ្លាច, ខ្លាចអាចម៍ខ្លា

ពាក្យនេះជាពាក្យពោលបញ្ឆិត

ជាសំនៀនពួកអ្នកខ្លាយគំនិត   ដែលគិតកោតខ្លាចខុសទំនង ។
ដូចម្ដាយឪពុកឬគ្រូបា   រក្សាកូនសិស្សដោយស្ងួនគ្រង
កូនសិស្សគោរពកុំឲ្យច្រួង   រំលងរំលោភលើលោកណា ។
ប្រសិនបើកូនសិស្សកោងកាច   ពុំខ្លាចគ្រូ-មាតាបិតា
ទៅខ្លាចឯអ្នកក្រៅមេបា   ហៅខ្លាចអាចម៍ខ្លា, ខ្លាម៉ិនខ្លាច ។
កូនសិស្សបែបនេះមានដំនៀល   តិះដៀលអំពីសំណាក់ប្រាជ្ញ
ដូច្នេះត្រូវកូនសិស្សកោតខ្លាច   អំណាចមេបាគ្រូប្រដៅ ។

## ៣២- ខ្លួនផាប់ទ្រព្យលាញ, ខ្លួនរស់របស់ចាន

ពាក្យនេះជាពាក្យពោលត្រង់ៗ

ដើម្បីឲ្យមនុស្សមានចំណាំ   ទឹកចន់ថែទាំជីវិតប្រាណ ។
កុំពេលឈឺថ្កាត់គ្រូនរង៉ា   ទំរើលឲ្យជាឲ្យស្មោះស្មាន
ដើម្បីជីវិតសុខក្សេមក្សាន្ត   ទើបបានរក្សាទ្រព្យសម្បត្តិ ។

ប្រសិនខ្លួនឆាប់ទ្រព្យទាំងឡាយ　　មុខជាអន្តរាយខូចខាយខាត
លុះតែខ្លួនរស់ទើបប្រយ័ត្ន　　ថែទាំសម្បត្តិឲ្យគង់បាន ។

## ៣៣ - ខ្លៅវែងស្អប់ប្រាជ្ញ

ពាក្យនេះពោលត្រង់មិនប្រស្នា

តាមរឿងដែលពិតជាធម្មតា　　នៃមនុស្សពាលខ្លៅអប្រិយ ។
ថាមនុស្សដែលខ្លៅឆៅគំនិត　　តែងគិតក្អាត់ក្អាំងតាំងស្មារតី
យកខុសជាគាប់មិនគប្បី　　មិនស្តាប់សេចក្តីប្រាជ្ញទូន្មាន ។
ទោះស្តាប់ក៏មិនឲ្យជឿជាក់　　មិនយកទុកដាក់ក្នុងសន្តាន
ប្រាជ្ញណាសន្តោសចំពោះប្រាជ្ញណា　　ប្រាជ្ញនោះច្រើនបានទោសពីខ្លៅ ។
ព្រោះខ្លៅសាមានទ្រសន្តានកាច　　រមែងស្អប់ប្រាជ្ញដែលប្រដៅ
តែប្រាជ្ញមែនពិតគំនិតជ្រៅ　　មិនតតបនឹងខ្លៅឡើយ ។

## ៣៤ - គាប់ចិត្តស្រាជាចិត្តចាយ

ពាក្យនេះជាពាក្យដាស់ស្មារតី

ដល់អ្នកដែលកើតមានការអ្វី　　គប្បីពឹងគេឲ្យជួយផង ។
បើអ្នកណាមួយមានការណា　　លុះត្រាតែអ្នកនោះប្រឹងចង
ចិត្តគេអ្នកជួយច្រើនកន្លង　　ឲ្យសមទំនងតាមការនោះ ។
គឺផ្គាប់ដោយគ្រឿងដ៏គាប់ចិត្ត　　ទើបគេអាណិតដោយចិត្តស្មោះ
ខ្វល់ខ្វាយប្រឹងប្រែងជួយសង្គ្រោះ　　ការនោះឲ្យបានដូចប្រាថ្នា ។

បើមិនដូច្នោះអស់លោកអ្នក ដែលជួយផុះមិនមេត្តា
ហេតុនេះបោកណទើបពោលថា "មនុស្សគាប់ទឹងស្រាជាទឹងបាយ" ។

## ៣៥- គេស៊ីពង, ឯងរងសំបុក

ពាក្យនេះជាពាក្យល្អវិសេស

ជាស់គៀនកុំឲ្យសើះពក្វែះ ប្រហែសក្នុងកិច្ចការទាំងឡាយ ។
បើមានកិច្ចការណាទាក់ទង ជាមួយអ្នកផងត្រូវខ្វល់ខ្វាយ
ប្រយ័ត្នក្រែងលោកើតអន្តរាយ មានទុក្ខដល់កាយឥតអំពើ ។
ដោយមានអ្នកណាគេមានល្បិច តែគេបលើក ទាសខ្មាក់លើ
ខ្លួនគេបានលាភល្អគ្រាន់បើ អាក្រក់ខាតទៅលើរូបខ្លួន ។
ដូចគេស៊ីពងពេញបន្ទុក សល់តែសំបុកមិនមាំមួន
ទើបឲ្យឯងរងពេញសំនួន ព្រោះខ្លួនប្រហែសមិនបេះកល់ ។

## ៣៦- គោលឿនស៊ីកាកា, ស្រីល្អស៊ីកាកូន

សុភាសិតនេះជាគាថា

ពោកណប្រៀបធៀបប្រៀបឧបមា អំពីធម្មតាមនុស្សទាំងឡាយ ។
ដែលមានចំណេះចេះការណា ថ្លៃថ្លាគ្រាន់បើប្រសើរសាយ
អ្នកផងច្រើនជ្រកមកអកប្រាយ ពឹងឲ្យខ្វល់ខ្វាយធ្វើការនោះ ។
ការពឹងនោះជួនក៏មានផល ជួនកាលនាំខ្វល់អំពល់ស្មោះ
តែត្រូវតែធ្វើដោយសង្គ្រោះ ចំពោះឈ្មោះអ្នកដែលមកពឹង ។

ម្នោះហើយលំបាកដូចគោល្បឿន មានល្បឿនបោលល្បីថ្មីលើផែនដី
ដែលគេច្រើនប្រើឲ្យបោលរឹង ត្រូវតែរំព្រឹងចាស់ស័កក ។

៣៧- គោដ្អើលមិនគិត, គិតតែជាស័ក្តា

សុភាសិតនេះប្រៃពិត

បោកណាលោកពោលជាប្រឹង ឲ្យមនុស្សបេះគិតខាតបំរើន ។
លោកថាការណាល្អប្រសើរ គួរធ្វើដំណើរឲ្យបានកើន
ការមិនចុះគួមកុំកើន ក្រកើនគិតគូរឲ្យយូរពេល ។
ការណាល្អស្អាតខ្ជួបខាតទៅ នោះត្រូវគិតតែលៃគ្មាន់គួរ
ឲ្យដឹងកលកិច្ចល្បិចជើងកេល រកពេលបំពេញទៀតវិញពិត ។
កុំគិតជំងាស់ឲ្យឆាស់ការ ដ៏មានខ្ញុំមសារឲ្យរឹបរឹត
បើបោះបោកណាថាប្រឹង "គោដ្អើលមិនគិត ។ជាស័ក្តា" ។

៣៨— គោខ្មៅដំបៅខ្នង ក្អែកហើរលងរំសាយកន្ទុយ

ពាក្យនេះជាពាក្យពោលប្រឹង

ចំពោះពួកអ្នកដែលមានចិត្ត ជាមជិតរង្គៀសរអៀសខ្លួន ។
គឺដូចអ្នកណាកើតរឿងអ្វី ហើយមានគេស្ដីបែបរ៉ុក្ខួន
ជារឿងផ្សេងទៀតប្រឆួន លើរឿងនៃខ្លួនផ្ទួនជិតៗ ។
អ្នកនោះតែងមានចិត្តរង្កៀស រអៀសកើបស៊ើបក៏ឆកិត
ដោយរឿងកំរខ្លួនផ្ទួនគ្នាពិត ទើបគិតរអាររអៀសឯង ។

(នៅមានត)

សាសនាវតារ

សង្ខេប

# លោកអាចារ្យ មៀវ-ឆន្ទ ឆន្ទត្ថេរ

មហាបរិយត្តិឧត្តមវិជ្ជាវត្តបន្ទាយមៀន ឃុំមៀន កោះសុទិន កំពង់ចាម

បានរៀបរៀងជាពាក្យកាព្យ

## រឿងសាសនា

សូមរៀបពប់រឭមរឿងសាសនា ព្រះចមកពប់កិនជិនសីហា
ជាសាស្តាចារ្យស្តែងថែងប្រត្យក្ស ៗ ជាគ្រូសព្វគ្រប់សាសន៍ក្រាស់
សីលសុទ្ធ ជាពុទ្ធបុត្រផុតផែនដែនសក្យៈ ពូជចំបង៉ប៉ងបានជាស្តេចចក្រ
សមអន្តរ្យស័ក្តិអនន្តកណ្តាលដី ៗ រិទ្ធិរឿងរុងខ្ពង់ខ្ពស់យសអនេក
អភិសេកឯកអគ្គទ្រង់សួស្តី បានជាក្សត្របាត់ខ្សត់រតនំពង្ស តែជប់បន្ទាំ
គត់រត់ចោលស្ថាន ៗ បំពេញផ្នួសបួសក្ខករកៀនក- រាំងកេតគ្រា
គ្រានាំវិខាន កុំឲ្យមកផ្ទែតជ្រៀតបៀតបៀនបាន ស្រួលសំកនស្រាន្ត
ស្រស់អស់តណ្ហា ៗ រួបចំណោះបេះឯងថែងជាក់ច្បាស់ បំបាត់ចាស់
ឈឺចាប់ស្លាប់សោកា សំដែងធម៌ល្អស្តាប់ច្បាប់សាសនា ថាសាស្តាស្តុក
ស្តុម្ភចំណានស្រស់ ៗ ជនទាំងពាន់ជាន់នោះលុះលង់ជឿ ចោលជំនឿ
ជាន់ចាស់ផ្លាស់បេញអស់ ប្រព្រឹត្តព្រះសាសនាមហាបុរស ថែរបង់
ចោះថែបព្រាហ្មណ៍តាមធម្មតា ៗ

កាលព្រះពុទ្ធនិព្វានមានសាវក ប្រាជ្ញប្រច័ក្សពេះចប់សព្វសាសនា ប្រព្រឹត្តតែងប្រឹងតងមិចរិយា ជាតម្រាតម្រាប់ច្បាប់បាលី ។ និព្វានទៅនូវពារអង្គារពិត ព្រលឹមល្មឹតផិតចែងសែងសុរិយ៍ ខែពិសាខឆ្នាំម្សាញ់ពេញបូណ៌មី ចូលអាសាឍមាសបីខែធួន ។ ទើបព្រះសង្ឃសីលសុទ្ធបុត្រសក្យៈ ព្រះកស្សបៈជាអាទ៍ឆ្លាតមាំមួន សិងចួបចុលជំនុំជុំរៀងខ្លួន រាប់ចំនួនប្រាំរយរូបអរហន្ត ។ ស្តេចអជាតសត្តតាំងតាក់តែង ទីកន្លែងថ្វាយសង្ឃក្នុងតម្បន់ ជិតគុហានាមាសត្តបណ្ណ តាត់ជាមណ្ឌបាជាមតោមតើតឆាយ ។ ទៀបភ្នំវេភារមគធរដ្ឋ មត់មូលមាត់មន្តសង្ឃបន្ទំថ្វាយ ឲ្យគង់គិតប្រែកប្រួររៀបចែកចាយ ធម៌ទាំងឡាយក្លាយឃ្លៀងឃ្លៀងជម្រង់ ។ ព្រោះព្រះពុទ្ធជម្ចាស់ត្រាស់សំដែង ច្រើនកន្លែងច្រើនស្ថានបានបាក់បង់ មិនទាន់មានគម្រាបរផ្ចិតផ្ចង់ ជំនុំសង្ឃចាំចប់សព្វសេចក្តី ។ ទាំង ៥០០ រូបសង្ឃអង្គអរហន្ត ព្រះអានន្ទចាំមាត់ស្ទាត់ល្បាញល្បី កស្សបត្ថេរៈអធិបតី ឧបាលីស្ទាញស្ទាត់ឋទបញ្ញត្តិ ។ ព្រះកស្សបៈដាក់ពាក្យសាកសួរសប អានន្ទតបប្របប្រាប់ក៏ប់រងកាត់ អាងបានទាន់បណ្តាំចាំគ្មានបាត់ ចំណែកអត្ថបាត់ធម៌ពណ៌នា ។ ឧបាលីថ្វីមាត់ស្ទាត់វិន័យ ឆ្លើយប្រពៃលៃឡាកបាត់ជាឃ្លា ក្រមជំនុំជុំចួបរួបរួមគ្នា សម្រេចជាបែបមួយជួយថែថួន ។ សូត្របញ្ចុះស្រុះស្រួបអបអានត្រៃ-បិដកថ្ងៃថ្ងៃក្រោយឲ្យខ្ជាប់ខ្ជួន លើកវិន័យលៃវគ្គដាក់

ដោយខ្លួន គិតចំនួនគម្ពីរវិន័យប្រាំ ៗ ព្រះសូត្រសោតដោតក្រងចង ដោយឡែក ប្រាំចំណែកគម្ពីរទីចំណាំ បរមត្ថកាត់ចិត្តល្អិតប្រាំ គម្ពីរ ប្រាំពីរប៉ែកចែកជាក្បួន ៗ សង្គាយនាជាភាសាបាលី បិដកបីលៃ បកគត់ចំនួន ប្រាំបីម៉ឺនបួនពាន់ខន្ធដោយខ្លួន រាប់សព្វសួនផ្ទួនសាំប្រាំ ពីរទេ ៗ ថែបចំណានបានចាំចំណាំស្ទាត់ រៀនពីមាត់គ្នាជាហូរហែ គោលសំខាន់កាន់ប្រិតឥតប្រួលប្រែ មិនហ៊ានកែប្រែរបង់សង្គាយនា ៗ

កាន់យ៉ាងនោះលុះលង់យន់យូរឆ្ងាយ ក៏ប្រែក្លាយយោបល់យល់ខុសគ្នា មួយរយឆ្នាំពីព្រះលះជន្មា បង្កើតជាវិវាទឃ្លាតច្បាប់ចាស់ ៗ ភិក្ខុអក នៅក្នុងក្រុងវជ្ជី ពោលអំពីបញ្ញត្តិកាត់ចោលខ្លះ កែបន្ថែម ១០ យ៉ាងកាង ប្រច្រាស់ សឹងមានច្បាស់ក្នុងច្បាប់ប្រាប់គ្រប់សព្វ ៗ ព្រះយសត្ថេរលី-លា ក្រោធឹងផល់ គោឡាហលកលកែប្រែទាំងដប់ មិនពេញចិត្តគិតតាំង ពាំងឲ្យស្ងប់ ទើបត្រឡប់កែរលករករើសគ្នា ៗ បាន ១ ក្រុមធំក្រៃលដែល គ្រប់គ្រង ត្រូវទំនងតាមត្រូវវេលា ប្រាំពីររយរូបអង្គសង្គាយនា ក្នុងវត្តវាលុកាជាអារាម ៗ ប្រែបក្រុងវេសាលីប្រាំបីខែ កាត់ពាក្យកែរលំពុំ យកតាម រឿងបំផ្លើសលើសធុរត្រូវឃាត់ហាម មិនឲ្យជាមជាបដរត ទៅឆ្ងាយ ៗ រាជសម្បត្តិរដ្ឋបាលកាលក្សត្រា នាមកាឡាសោកពជវឌ្ឍី សាយ ព្រះអង្គព្រមជាមួយជួយខ្វល់ខ្វាយ ខាងទិកាយជាន់ចាស់ផ្សះ ផ្សាគ្នា ៗ សមាគមជំរះលះរឿងថ្មី រៀងបាលីពយរៀបរបៀបឃ្លា

សូត្រសម្រេចអបអានបាននាមា ហៅថាត្រាទីពីរសង្គីតិ ។ ឯពួកខាងវជ្ជី ពីកាលនោះ ក៏វែរុះសំខាន់កាន់ទិដ្ឋិ មិនព្រមប្រេបតបតប្រែវណ៌ា កើត អស្មិមានាជាពួកបក្ខ ។ ទើបព្រះសង្ឃសងខាងគាងនិកាយ ក៏ដើរផ្សាយ ធម៌អាថិសាសនៈ វង្វេងយោបល់ខ្វល់ខ្វាយក្លាយបែកបាក់ ជាគណៈពីរ ក្រុមធំក្រាស់ក្រួន ។ ពួកវជ្ជីបាននាមតាមគេដាក់ ឧត្តរនិកាយផ្សាយ ច្បាប់ក្បួន ទៅឧត្តរខ្វះខ្វាយឆ្ងាយមាំមួន ផល់ចិនយួនមង្គោលបច្ចូលតៅ-លី ។ និងទីបេតហើយវៃឯបូតាំ ដល់ភាកផប៉ុនសីបេរី ចំណែកទិស បស្ចិមត្រឹមប៉ុស្តិ៍ ស៊ឹងជាទីសំខាន់កាន់សាសនា ។ ឯពួកសង្ឃត្រង់ ត្រាប់ច្បាប់សាវក ទក្ខិណនិកាយប្រាយប្រាជ្ញ ប្រព្រឹត្តគង់ប្រឹងគធម៌ ចរិយា ទៅទិសខាងត្បូងហូងវែងឆ្ងាយ ។ ព្រះសង្ឃផងសងខាងសាង សាសនា ត្រាច់យាត្រាលាយឲ្យរំខ្វល់ខ្វាយ ពួកឯនាយឆ្ងាយមកកេក ខាងអាយ ខាងឯងផ្សាយណាយគេផ្សេចម្រុះ ។

លុះវេលាត្រាក្រោយខ្សោយសាមគ្គី ពួកទាំងពី(១) មិនកែតែប៉ុណ្ណោះ កន្ទិកាយដូចគ្នាឃ្លាឃ្លាតខុស ក្លាយសាយសុសកុះកើនច្រើនគគណ ។ ពួកឧត្តរក៏គិតកែបំភ្លៃ ធម៌វិន័យនាំប្លែកបែកបាក់ធ្ងន់ រីងពីរុធពុទ្ធឧស្គុះ ទាបទទំ ទៅជាមន្តបន្សាបអាបឧទ្ធព្រាយ ។ ឯមគធជាទីពីដើមគ្រាន់ លុះដំនាទជាន់ក្រោយខ្សោយកាយមាយ មិនព្រមព្រៀងទៀងទាត់កក់ ពេពេកយ ប្រឡំលាយលទ្ធិគ្រន្ថក្រាស់ ។ សកកជរពាង់ជាងពីរយេ

---

១ ពីរ ។

រំភើបញយញាប់ញីកវឹកវរផ្កាស    បន្ទព្រះសង្ឃបង់សត្យបាត់សង្វាស
សង្វេគណាស់នាំឲ្យខ្សោយស្រែកស្រេក ។

សម័យមួយក្សត្រក្សាន្តមានបារមី ត្រង់បុរីវង្គាបាដលីបុត្ត ជាស្ដេចផែនមគធៈជាក់ចំហុត ព្រះចមមកុដផុតគិតវិត្តពល ។ នាមអសោក-កជាក្សាតេជះ ជយជំនះឈ្នះលុបកពមណ្ឌល សឹកញញើតខ្មើតខ្មាតឃ្លាតខ្លាចផល់ ទីងតទល់យល់តឹងប្រឹងមិនបាន ។ ព្រះគួរនេរនាថជាតិបណ្ឌិត ព្រះទ័យគិតជឿជាក់ស្ម័គ្រស្មោះស្មាន ប្រព្រឹត្តធម៌ព្រះពុទ្ធផុតកពស្មាន ទ្រង់កប់អានឥតឯវែរបុង់បោះ ។ សាសនូបត្ថម្ភបំរុងកស្រ្ត ប៉ាជ្ញាឈ្មាសត្វាគន្ធៀរស្រៀវស្រេចស្រស់ គ្រាព្រះសង្ឃសូន្យគ្រឹត្យល្អិតល្អោចអស់ ព្រះអង្គដោះទុក្ខព្រួយជួយជំរង់ ។ សព្វព្រះទ័យតាមលោកមោគ្គលីបុត្ត សីលវិសុទ្ធឧត្តមសំដីត្រង់ ប្រោសប្រទានតាំងជានាយកសង្ឃ បំបាត់បង់សង្ឃបាបសាបសូន្យសៀង ។ ភិក្ខុ-សង្ឃបង់សាកពាក្យពំទី ព្រះមោគ្គលីចោទចាប់ស្ដាប់ផ្ទាត់ផ្ទៀង ភិក្ខុណាជាខុសបុះលំអៀង មិនចាត់ទៀងតាមច្បាប់អាប់សាសនា ។ បរមក្សត្រចាត់ដាក់ទ័ទទន់ គឺទ្រគ្រនូរក្រៅសាសន៍ផ្កាសសាក់ មកបួសក្នុងស្ទើងលាកពាបពុទ្ធដីកា ដាក់អាជ្ញាដកចេញដេញចោលអស់ ។ ភិក្ខុណាបរិសុទ្ធបុគ្គសក្យៈ ថ្លើយមិនអាក់ស័ក្តិសមចំឥតខ្ចោះ ទ្រង់មេត្តាត្រាទុកមុខស្រស់ចស់ កប់អានស្មោះចំពោះព្រោះសត្ថា ។ លុះកំចាត់បាត់

បង់សង្ឃក្អែងក្អាយ ទាន់និកាយថេរៈគាត់តែងជា ទីប្រជុំធំចៀបរៀប
សភា សង្គាយនាវេលាត្រាទីបី ។ ក្នុងអសោការាមតាមដំណើរ ក្សត្រ
ប្រសើរសូមសុំក្រុមគីរី ព្រះមោគ្គលីទីប្ដេក់អធិបតី តែសេចក្ដីបិដកគក់
ទាស់ខុស ។ សមាជិកភិក្ខុសុបញ្ញា សាគច្ឆាសំរេចផ្ដាច់កំហុស យល់
ព្រមព្រៀងរៀងប្រាណអានបញ្ចុះ ឲ្យស្រួលស្រុះស្របគ្នាជាបែបមួយ ។
ស្ដេចអសោកសិទ្ធិស័ក្ដិបក្រពត្រា ផ្សាយសាសនាគ្រែកលើកចំមួយ មាន
ព្រះសង្ឃសោភាជាជំនួយ ចេញទៅជួយបែកគធម៌ថ្លៃថ្លា ។ ឯអសោក
ភូមិន្ទពិនរៀងជ័យ ជាប់ព្រះទ័យជឿស្ញុងក្នុងសាសនា ស្រឡាញ់លុប
ទ្រព្យធនជន្ជូជីព៌ ជាងជីវិតកាយាសរពើផង ។ កំពុងត្រែងពង្សម្យេពុំ
ការង់ ចេញទៅទ្រង់ព្រះផ្នួសបួសបានម្ដង លះសិក្ខាលាគេទចេតនាបង់
បំពេញកង់កុសលផលបុណ្យមាន ។ វិន័យធម៌ខ្ជួរខ្ជប់គ្រប់នគរ ព្រះ
កូជនេរនាថឃ្នាតរុតកន តាក់បណ្ឌិតគិតជ្រៅទៅមុន្នាន ធម៌ជាយាន
យោងសត្វបាត់បង់បាប ។ ព្រះពុទ្ធពេចន៍លេចលាន់ជាន់នោះណាស់
ល្អត្រចះរឿងរុងគង់ជកប បរិស័ទស័លសុទ្ធលុតឱនក្រាប មិនឲ្យសាប
ជាបដុនបុណ្យសាស្ដា ។

ទីងលើកឡាត់កាត់កោលពោលស្រូតរូត រឿងកជចូតជាំងឡាយ
ផ្សាយសាសមា ក្នុងជុងផែនផែនកពលឃប់ចរពា ពោករចំពោះលង្កាកោះ
ស្រស់ស្រាយ ។ មហិន្ទត្ថេរកេនុរសក្សត្រ ទទួលបាត់ជំរូវផ្លូវផ្ដាច់ឆ្ងាយ

ដល់លក្ខការស័ព្ទប្រាប់ចើតធាយ ជនទាំងឡាយឡើងប៉ិត្តស្និទ្ធស្នេហា ។ ទទួលស្ដាប់ត្រាប់ត្រងចង់ជឿជាក់ ទាំងខត្តិយៈជ្ញាក់ពាសកស្រុកធម្មកា ខ្ញុំ ក៏បួសបង់ផ្ទះលះកាមា ទាំងទ័ព្យាត្រាត្រៀបពៀបពោរពេញ ។ កាលព្រះសង្ឃកើតកើនច្រើនដល់ម៉្លោះ ក៏ស្រួលស្រុះចុះចិត្តប្រិតខ្ទេញ បិដកបីថ្វី មាត់ស្ទាត់ជុំវិញ ពេលនោះម៉ិញពេញរៀងឡើងអស្ចារ្យ ។ ព្រះមហាថេរ មេគណៈ រួមមិត្តភ័ក្តិរៀបរៀងរៀងធម៌អាថ៌ សូត្រឲ្យសមចំស័ព្ទស្ដាប់ វិហារ ទុកជាការទៀងទាត់វត្តប្រតិបត្តិ ។ លុះកន្លងវេលាជាចំណោរ ពួក ព្រះថេរធំៗក្រុមបរិស័ទ សមាគមជំរះព្រះបរិយត្តិ ហើយថែងហត់ហាក់ ជាក់ស្ទុកកិត ។ តាំងពីព្រះទិញ្ញានគ្មានសាស្ត្រា សាសនាចាំស្ទាត់មាត់ បណ្ឌិត ទើបព្រះសង្ឃលក្ខាហាពិនិត្យ ដោយការគិតត្រូវបំដំបូងដៃ ។ ពួកបណ្ឌិតមិត្តភ័ក្តិអ្នកប្រាជ្ញប្រាយ អធិប្បាយបាលីបិដកត្រ័យ ពាក្យ បន្ស៊ៀតឆ្ងៀតតែងថែងតែថៃ ឧបមេយ្យឧបមាត្រាស្ដាប់បាន ។ ហៅ អដ្ឋកថាហាដាច្បាប់ ទុកសម្រាប់រៀនហាត់ស្វាធ្យាយអាន ទើបទីព្ធជាន់ ក្រោយដោយសណ្ដាន ថែបចំណានពីកេះឈ្មោះដីកា ។ ត្រូបិដកបីកាត ពាក្យបាលី តរថៃបច្ចុប្បសំដីសីហឡ ទុកជាស្ទូលបណ្ឌលគោលសាសនា សូត្រសិក្សាហារីកហ៊ឹកហ៊ឺនហាត់ ។ លុះកន្លងវេលាយារយូរណាស់ វស្សៈ ទ័១០កប់រៀបកាត់ ដែលត្រណ្ឌៀដោះជាសត្រាស់បរិស័ទ តែវិបត្តិក្បួន ច្បាប់អាប់អួនអស់ ។ មានបុរសស្រស់ចើតកើតនៅនា ស្រុកពុទ្ធគយា

គ្រាកំឡោះ លះសន្ទានស្ពានស្និតឥតស្រណោះ បួសដោយស្មោះដោះ
កាយថ្វាយសាសនា ។ នាមពិរោះឈ្មោះពុទ្ធឃោសៈ ប្រាជ្ញាពាក់ចេះ
ចប់សព្វសាស្ត្រា ក៏បានធ្វើសំពៅទៅលង្កា យកដម្រាបាលីបិដកត្រៃយ ។
ទៅផ្ទៀងនឹងបាលីសីហឡា ពួកលង្កាសាទរអរពេកក្រៃ សឹងព្រមគ្នា
ជាមួយជួយពួតដៃ លុបកែខពាក្យខុសកុះហុតហួន ។ ទើបព្រះពុទ្ធ-
ឃោសាចារ្យចែងចាត់ ត្រួតទាំងអដ្ឋកថាដីកាផង ច្បាប់ចំណានបាន
ការចារចំឡង ច្បាប់ក្បាយធ្វើមិនសុទ្ធដុតគ្មានសល់ ។ ហើយប្រែពី
បាលីសីហឡៈ ជាមគធភាសិតឥតសំណល់ នាំមួយចប់ឡប់យកមក
ដំកល់ ដំកើងដល់បុរីដ៏មគធៈ ។

សាធរេនពេនផេន ដែលជាប់ពន្ធជៀពិគគិតបញ្ជាក់ ចូរសង្កេត
រកចកាន់ឥន្ទធុរៈ មានលោកអ្នករៀបរៀងទៀងប្រពៃ ។ ឯខ្មែរយើង
ដើងតាស់សាសន៍បុកណា ប្រើទកប់អានអ្នកតាអារក្សព្រៃ ព្រាយ
បិសាចភូតណាស់ខ្លះគិតភ័យ ខ្លាចទំនៃលែលកយេកធ្វើគ្នា ។ ព្រៀង
សក្ការស្វាធមព្រមបាយសី និចំណីចំថោងគោនបូជា លើកអារក្សដាក់
ពេរ៉ធ្វើគ្រូត្រា ខ្លាចបានជាទៅហ្វាយកាយប្រែសស្រី ។

លុះវេលាជ្រាព្រាហ្មណ៍ទាមភារស្រុក ធ្វើអុកឡុកលុកប្ងន់ជំណ្ដ៏មដី
ខ្មែរក៏បែរស្រុះថ្វាសាជាថ្មី តាមសំដីពួកជ្រាត្រានោះឯង ។ កាន់ដម្រាប់
ដម្រាសាសនាព្រាហ្មណ៍ គោរពនាមព្រះព្រហ្មចំបំពែង ព្រះឥសូរ

អង់អាចកាចគួរស្ញែង នារាយណ៍តែងស្រោចស្រង់សង្គ្រោះសត្វ ៗ
ព្រះទាំង ៣ ថ្វីដៃថ្លៃថ្លាស្រស់ ជួយប្រោសប្រោសរំដោះគ្រោះកាចកាត់
ឲ្យសះស្បើយកេតាជាដំកាត់ ស្ងប់វិបត្តិស្ងាត់ភ័យជ័យមង្គល ៗ

នៅឆ្នាំប្រាំពីររយក្រោយសកកដ មានអ្នកប្រាជ្ញពុទ្ធសាសន៍ថ្លាស
ប្រដិពល សាសន៍ឥណ្ឌាសៀមេក ដែកដែកទល់ ធ្វើតពន្យល់សាស-
នាមហាមុនី ៗ ទុត្តនិកាយក្លាយហៅថា ជាមហាយានៈជាក់ពេញទី សឹង
មានមកយូរយារគ្រាកាលពី ទុតិយសង្គីតិនោះឯង ៗ នាំឲ្យខ្មែរបែរ
ប្តាក់ស៊ុគ្រប់ចិត្តពាស នាហ៊ឹនកស្តុកប់ស៊ប់គ្រប់គខ្មែង កន្លងកាល
វេលាជាអង្វែង តាំងស្តេចស្តេងបក្រពង្សទ្រង់កាន់ផង ៗ

សកកដវាំងជាងពាន់ប្លាយ ទើបនិកាយទក្ខិណៈជាក់មកម្តង មាន
គេជឿជាក់ស្ញាទកាន់គឹកកង ព្រោះហ្មត់ហ្មងផ្លូវផង់ត្រង់ត្រូវស្អាត ៗ
ជានិកាយខាងត្បូងហ្វូងថេរ ឬហៅថាហីនយានមានក្រិតខាត ជាពួក
ពិតឥតល្អៀងទៀងសុទ្ធសាធ មិនខុសខាតជាតប្លែកបែកបែបបាស់ ៗ
តែមិនទាន់កើតមានវាំនសកស្តា ជាដម្រាមាំមួនរួនខ្ជាប់ណាស់ រៀនពី
គ្នាយារយូរគ្រប់តាស់ៗ មិនសូវច្បាស់ខ្វះលើសរើសជ្រើសផ្សំ ៗ

សកកដ ១ ពាន់កាន់ផុតឆ្ងាយ ប្រាំពីរយឆ្នាំប្លាយក្សត្រឧត្តម ត្រង
ដែនដីសីហឡៈអ្នកឧបត្ថម្ភ រើរៀបចំតាក់តែងតែងសាសនា ៗ និមន្ត
ព្រះកស្សបៈគណៈសង្ឃ ឲ្យដំរង់រៀបរៀងផ្ទៀងសាស្ត្រា សមសម្រេច

ស្រេចស្រស់រស់ស្អា ក៏បែបមានការឡើងថ្កើងជាថ្មី ។ ស័ហទ្យទ្វីបា មហាថ្កើងថ្កាន កេរ្តិ៍ណានខ្ចរខ្ចាយសាយសំដី សព្វនគរខ្ចូរខ្ចប់លុះឮល្បី មកសូមខ្ចីសាស្ត្រាតារជាច្បាប់ ។

ព្រះសង្ឃកម្ពុជាព្យាយាមតែ គ្មានអាល័យជីវិតគិតខ្លាចស្លាប់ ធ្វើដំណើរដើរឆ្ងាយកាយយាក់យ៉ាប់ ព្រោះចិត្តចាប់ចង់យល់គល់សាសនា ។ ចេញចាកជនបទដែនខ្មែរ ព្រះភក្ត្របែរចំពោះកោះលង្កា រៀនចំណេះចេះស្ដាប់ស័ព្ទភាសា ក្បួនធម្មាបកបែរប្រែខ្មែរបាន ។ ហើយចំឡងចងតារសរពើច្បាប់ វិលត្រឡប់នាំយកមកវិញថ្កាន ជនទាំងឡាយស្មោះសរអរគ្រប់ប្រាណ ប្រឹងរៀនអានគោរពគ្រប់កាយា ។ ឯព្រះសង្ឃអង្គខ្លះឈ្លាសសេចក្ដី ប្រែបាលីនានាជាខេមរ ដូចយើងធ្លាប់ឃើញស្រាប់ច្បាប់វេទនា ជាសាស្ត្រាទំព័រជាន់បុរាណ ។ ពីដើមជាភាសាបាលីសុទ្ធ កុលបុត្រជាតិខ្មែរប្រែមិនបាន អាស្រ័យបែបបកប្រែតែគ្រប់ប្រាណ សំរាប់អានមើលមៀងឆ្មៀងពុទ្ធដីកា ។

កម្ពុជាបុរីបុរាណ គេរាប់អានសំខាន់កាន់សាសនា ចំណាយទ្រព្យរាប់លានមានប្រាថ្នា ឲ្យមហាជនចៀសគៀសផុតភ័យ ។ សាងអារាម តាមស្ថានបានស្ថិតស្ថេរ ទុកជាគ្រឿងលម្អប្រពៃ ជួយវិចិត្រស្អិតស្អាង សាងរៀងជ័យ ជាស្ថាននៃវេទនាមហាជន ។ ដូចពដការជាន់ចុងថ្មីដែលស្រស់

តាំងរបស់នានាជាគំនរ សំរាប់មើលកំសាន្តបានសាទរ ឲ្យខ្ចរខ្ចរ
គេត្រៀឈ្មោះពិរោះឆ្ងាយ ។ ចិញ្ចឹមសត្វតាត់ ប្អូនក្បួនរចនា សួនបុប្ផាសារភាព
ពបតេគផាយ ចំណាយទ្រព្យៗប់លានគ្មានទឹកស្ដាយ ឲ្យសប្បាយដល់
ក្រស្ត្រតាសទូទៅ ។ ធរណីទីវត្តពុទ្ធសីមា ជាសាលាសិក្សាជាលំនៅ
បណ្ណាល័យលោកតាំងក្រាំងសៀវភៅ ច្បាប់ភាគជ្រៅជ្រាមវែងផងវែង
ផ្ទះថ្មា ។ ក្មេងទាំងទ្វេវ័យតិចកិច្ចត្រូវហាត់ មានសម្បត្តិឬទ្ធិពលកាយា
ឲ្យតែប្រុសពោះអ្នកអនាថា ក៏សិក្សាតាមចិត្តឥតចេញថ្លៃ ។ ក្រស្ត្រអ្នក
ស្រុកសុខចិត្តឥតទៀយណាយ ជួយចំណាយបាយទឹកព្រឹកល្ងាចថ្ងៃ
ទីដំណេកដេកដាក់ស្នាក់អាស្រ័យ ជួយកែខៃឲ្យជាតិឃ្លាតល្ងង់ខ្លៅ ។
របៀបកិច្ចរបបការស្មាធ្យាយន៍ រៀនទិយាយសមគួរសួរញាតិផៅ រៀន
សរសេរកំណត់កត់សំញៅ ពាក្យប្រដៅផ្លូវលោកយោគធម៌អារ្យ ។ ខ្មែរ
បុកណរបានពីងទីងទីវត្ត រៀនបេះស្លួតបានព្រមល្មមប្រើការ វត្តទទួល
ផប់លៀងស្បៀងអាហារ គ្រូអាចារ្យមិនបាច់ជាប់ប្រាក់ខែ ។ ទីអារាម
តាមរៀបចៀបដោយពិត ដូចជីវិតជីវិតឪម៉ែ ផ្តុកបា្ប់ក្បួនផ្តួនផ្ចប់គ្រប់
គ្រងថែ កុំបានតែប៉ុណ្ណោះម៉េះសមស្នាក់ ។ ខ្មែរមួយផ្នែកប៉ែកពួងរង់បាប
គ្រោះ ហេតុពីព្រោះគ្មានវត្តភ្នាក់វិបត្តិ អក្ខរៈលាក់ឈើប្រើបញ្ញតិ
បញ្ញាតាត់គិតស្មានអានផ្សេងផ្សេ ។

(នៅមានត)

# លោកគ្រូអាចារ្យប៉ាង-ខាត់ ប្រែនិងរៀបរៀង

(តមក)

ម្នាលមាលុង្ក្យបុត្រ! ព្រោះហេតុនោះ អ្នកទាំងឡាយចូរចាំទុកនូវសេចក្ដីដែលតថាគតមិនបានសំដែងហើយ (ព្យាករណ៍) តាមសេចក្ដីដែលតថាគតមិនបានសំដែង (ព្យាករណ៍) ហើយទាំងចូរចាំទុកនូវសេចក្ដីដែលតថាគតបានសំដែងហើយ (ព្យាករណ៍) តាមសេចក្ដីដែលតថាគតបានសំដែង (ព្យាករណ៍) ហើយៈនោះចុះ ។ ម្នាលមាលុង្ក្យបុត្រ! តថាគតមិនបានសំដែងសេចក្ដីដូចម្ដេចខ្លះ? ម្នាលមាលុង្ក្យបុត្រ! តថាគតមិនបានសំដែងថា "លោកទៀង លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះក៏គឺសរីរៈនោះ ជីវិតដទៃសរីរៈក៏ដទៃ សត្វស្លាប់ហើយកើតទៀត សត្វស្លាប់ហើយមិនកើតទៀត សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលមាលុង្ក្យបុត្រ! ព្រោះទិដ្ឋិនោះមិនប្រកបដោយប្រយោជន៍ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្ដីរលត់ទុក្ខ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងច្បាស់ ដើម្បីសេចក្ដី

ត្រាស់ដឹង ទីងដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតមិនសំដែងទិដ្ឋិនោះ ។

ម្នាលមាលុង្ក្យបុត្រ! ចុះសេចក្ដីដូចម្ដេច ដែលតថាគតតែងសំដែង, ម្នាលមាលុង្ក្យបុត្រ! តថាគតតែងសំដែងថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្ដិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ។ ម្នាលមាលុង្ក្យបុត្រ! ព្រោះហេតុដូចម្ដេចបានជាតថាគតសំដែងពាក្យនុ៎ះ ម្នាលមាលុង្ក្យបុត្រ! ព្រោះថាពាក្យនុ៎ះប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្ដីរំលត់ទុក្ខ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងច្បាស់ ដើម្បីសេចក្ដីត្រាស់ដឹង ទីងដើម្បីព្រះនិព្វាន ។

ម. ម. មាលុង្ក្យសូត្រ ២៣-២៥៣-១៥០

## កុំប្រកាន់ខ្ជាប់ក្នុងធម៌ តែប្ដូរប្រើគ្រាន់តែជាគ្រឿងសម្រាប់ឆ្លង

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា "ម្នាលភិក្ខុទាំងឡាយដូចជាបុរសដើរផ្លូវឆ្ងាយ បុរសនោះឃើញនូវអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យ មានត្រើយខាងនាយក៏ក្សេម ប្រាសចាកភ័យ តែថាទូកឆ្លង ឬស្ពានសំរាប់ចូងពីត្រើយអាយទៅត្រើយនាយ មិនមានដល់បុរសនោះឡើយ, បុរសនោះមានសេចក្ដី

ត្រិះរិះយ៉ាងនេះថា "អន្លង់ទឹកដ៏ធំនេះ មានត្រើយខាងអាយប្រកបដោយសេចក្ដីរង្កៀសនឹងភ័យ មានត្រើយខាងនាយដ៏ក្សេម ប្រាសចាកភ័យ ទូកក្បូនឬស្ពានសម្រាប់ឆ្លង ពីត្រើយខាងអាយទៅត្រើយខាងនាយក៏គ្មាន បើដូច្នោះមានតែអាត្មាអញប្រមូលស្មៅ កំណាត់ឈើ មែកឈើ នឹងចម្បើងយកមកចងធ្វើជាក្បូន ហើយអាស្រ័យនូវក្បូននោះ ព្យាយាមដោយដៃនឹងជើង ឆ្លងទៅកាន់ត្រើយខាងនាយដោយសួស្ដីបាន ។ ម្នាលភិក្ខុទាំងឡាយ! បុរសនោះក៏ធ្វើតាមគំនិតនោះ ហើយឆ្លងទៅកាន់ត្រើយខាងនាយបានដោយសួស្ដី កាលបុរសនោះឆ្លងទៅដល់ត្រើយខាងនាយហើយ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា "ក្បូននេះមានឧបការៈច្រើនដល់អាត្មាអញ, អញបានអាស្រ័យនូវក្បូននេះ ព្យាយាមដោយដៃនឹងជើងឆ្លងមកដល់ត្រើយដោយសួស្ដីបាន បើដូច្នោះមានតែអាត្មាអញលើកក្បូននេះទូលលើក្បាល ឬលើកលីដើរចេញទៅកាន់ទីគួរតាមប្រាថ្នា" ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយសំគាល់សេចក្ដីនោះថាដូចម្ដេច? បុរសនោះធ្វើយ៉ាងនេះ បានឈ្មោះថា ជាអ្នកធ្វើសេចក្ដីសមគួរដល់ក្បូននោះឬទេ? ។ បពិត្រព្រះអង្គដ៏ចំរើន! ហេតុនោះមិនមែនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ! ចុះបុរសនោះធ្វើដូចម្ដេច ទើបបានឈ្មោះថាធ្វើសេចក្ដីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ! បុរសនោះឆ្លងដល់ត្រើយកន្ទីឯណោះ គួរតែត្រិះរិះយ៉ាងនេះថា "ក្បូននេះមានឧបការៈច្រើន

ដល់អាត្មាអញ អញបានអាស្រ័យនូវក្បូននោះហើយ ព្យាយាមដោយដៃទាំងជើងខ្លួនមកដល់ត្រើយនាយបានដោយសួស្តី បើដូច្នោះមានតែអាត្មាអញ លើកក្បូននេះដាក់លើគោកឬពន្លិចទៅក្នុងទឹក ហើយដើរចេញទៅកាន់ទីគួរតាមប្រាថ្នា" ។ ម្នាលភិក្ខុទាំងឡាយ! បុរសនោះដែលធ្វើយ៉ាងនេះបាន ឈ្មោះថាជាអ្នកធ្វើសេចក្តីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ! ធម៌ឧបមាដូចជាក្បូនដែលតថាគតសំដែងហើយ ដើម្បីឲ្យរលាស់ខ្លួនចេញមិនមែនដើម្បីឲ្យនៅប្រកាន់ជាប់ឡើយ, ម្នាលភិក្ខុទាំងឡាយ! កាលបើអ្នកទាំងឡាយដឹងច្បាស់នូវធម៌ មានឧបមាដូចជាក្បូនដែលតថាគតសំដែងហើយ គប្បីលះបង់ធម៌ទាំងឡាយនុ៎ះចេញ(១) នឹងចាំបាច់ពោលទៅដល់អកុសលធម៌ ។

ម. មូ. អលគទ្ទូបមសូត្រ ១២- ៤៥- ១៨

## ប្រៀបអ្នករៀនអរិយសច្ច ដោយកណ្ដុរបួនពួក

ម្នាលភិក្ខុទាំងឡាយ! កណ្ដុរ ៤ ពួកគឺ កណ្ដុរធ្វើរន្ធតែមិននៅ ១, កណ្ដុរនៅតែមិនធ្វើរន្ធ ១, កណ្ដុរមិននៅផងមិនធ្វើរន្ធផង ១, កណ្ដុរធ្វើរន្ធផងហើយនៅផង ១; ម្នាលភិក្ខុទាំងឡាយ! នេះកណ្ដុរ ៤ ពួក ។ ម្នាលភិក្ខុទាំងឡាយ! បុគ្គលទាំងឡាយដែលឧបមាដូចជាកណ្ដុរទាំងឡាយ ក្នុងលោកនេះក៏មាន ៤ ពួកយ៉ាងនោះដែរ, បុគ្គល ៤ ពួកនោះតើដូចម្តេច? គឺ

១ សមថនឹងវិបស្សនា គឺឲ្យលះឆន្ទរាគៈ ក្នុងសមថនឹងវិបស្សនានោះឯង ។

បុគ្គលធ្វើរន្ទតែមិននៅ ១, បុគ្គលនៅតែមិនធ្វើរន្ទ ១, បុគ្គលមិននៅផង មិនធ្វើរន្ទផង ១, បុគ្គលធ្វើរន្ទផងហើយនៅផង ១ ។

១- ម្នាលភិក្ខុទាំងឡាយ ! បុគ្គលធ្វើរន្ទតែមិននៅនោះតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនបរិយត្តិធម៌ប្រកបដោយអង្គ៩ ប្រការ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ តែបុគ្គលនោះមិនដឹងច្បាស់តាមពិតថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនេះ ធ្វើរន្ទតែមិននៅយ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថាដូចជាកណ្តុរដែលធ្វើរន្ទតែមិននៅ ។

២ - ម្នាលភិក្ខុទាំងឡាយ! បុគ្គលនៅតែមិនធ្វើរន្ទនោះតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ! បុគ្គលពួកខ្លះក្នុងលោកនេះ មិនរៀនបរិយត្តិធម៌ប្រកបដោយអង្គ ៩ ប្រការមានសុត្តៈជាដើមទុំនេះ តែបុគ្គលពួកនោះដឹងច្បាស់តាមពិតថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនេះនៅតែមិនធ្វើរន្ទយ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថា ដូចជាកណ្តុរដែលនៅតែមិនធ្វើរន្ទ ។

៣ — ម្នាលភិក្ខុទាំងឡាយ! បុគ្គលដែលមិនទៅផង មិនធ្វើនូវផង នោះតើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកខ្លះក្នុងលោកនេះ មិនរៀនបរិយត្តិធម៌ ប្រកបដោយអង្គ ៩ ប្រការ មានសុត្តៈជាដើមទុះផង មិនដឹងច្បាស់តាមពិតផងថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនេះមិនទៅផងមិនធ្វើនូវផងយ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថាដូចជាកណ្ដុរដែលមិនទៅផង មិនធ្វើនូវផង ។

៤— ម្នាលភិក្ខុទាំងឡាយ! បុគ្គលដែលធ្វើនូវផងហើយទៅផងនោះតើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកខ្លះក្នុងលោកនេះ រៀនបរិយត្តិធម៌ប្រកបដោយអង្គ៩ ប្រការ មានសុត្តៈជាដើមទុះផង ដឹងច្បាស់តាមពិតផងថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនោះធ្វើនូវផងហើយទៅផងយ៉ាងនេះឯង; ម្នាលភិក្ខុទាំងឡាយ ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថាដូចជាកណ្ដុរដែលធ្វើនូវផង ហើយទៅផង ។

ចតុក្ក-អំ-២១-១៦៤-១០៣

(មានត)